# ប្រេង និង ឧស្ម័ននៅប្រទេសកម្ពុជា




ស្អាតស្អំ

រួមគ្នាប្រឆាំងអំពើពុករលួយ

## ផលិតដោយ

Pact Cambodia
BUILDING CAPACITY WORLDWIDE

Tel: (955-23) 217 855
Fax: (855-23) 217 856
Email: pact@pactcambodia.org
www.pactcambodia.org

## ប្រេង និង ឧស្ម័ននៅកម្ពុជា

© ខែកុម្ភៈ ឆ្នាំ ២០០៧

យើងលើកទឹកចិត្តឱ្យលោកអ្នក ថតចម្លងផ្នែកណាមួយ ឬផ្នែកទាំងអស់នៃសៀវភៅនេះ និងចែកចាយទៅអ្នកដទៃទៀត

## មាតិការឿង

មាតិការឿង ........ 1
សេចក្តីផ្តើម ........ 3
សាវតារ ........ 3
ការផលិត និងការចំរាញ់ប្រេង និង ឧស្ម័ន ........ 3
ក្រុមហ៊ុនប្រេង និង ឧស្ម័ន ........ 5
បញ្ហាច្បាប់ ........ 4
បណ្តាសាធនធាន ........ 9
គំនិតផ្តួចផ្តើមនៃតម្លាភាពឧស្សាហកម្មនិស្សារណកម្ម ........ 11
ការប្រើប្រាស់ប្រេង និង ឧស្ម័ន ........ 12
ផលប៉ះពាល់ខាងបរិស្ថាន និងសង្គម ........ 12
ការប្រើប្រាស់ចំណូលបានមកពីប្រេង និងឧស្ម័ន ........ 13
ប្រេង និងឧស្ម័ននៅក្នុងប្រទេសកម្ពុជា ........ 13
ការរុករកនៅក្នុងទសវត្សឆ្នាំ ១៩៩០ ........ 13
ប្លុកសំរាប់ការរុករក ........ 13
អាជ្ញាប័ណ្ណដែលបានផ្តល់មកទល់បច្ចុប្បន្ន ........ 14
ប្លុក A_ ឆេវរ៉ុន/មីតស៊ី/ជីអេស កាល់តិច (Chevron/Mitsui/GS Caltex) ........ 14
ប្លុក B- សឹង្ហបូរី/ភីធីធី/រីហ្សសហ្វុល និង/ឬ ស៊ីអ៊ិនអូអូស៊ី ឬ តូតាល់ Singapore/PTT/ Resourceful and/or CNOOC or Total ........ 15
ប្លុក E — ម៉េដកូ/ជីអេចអិល Medco/JHL ........ 15
ប្លុកផ្សេងៗទៀត ........ 16
ផលប៉ះពាល់ខាងបរិស្ថាន និងសង្គម ........ 16
ចំណូលដែលអាចមាន ........ 17
ក្របខណ្ឌច្បាប់ ........ 18
ច្បាប់មួយចំនួនដែលកំពុងប្រើទាក់ទងនឹងវិស័យប្រេង និងឧស្ម័ននៅក្នុងប្រទេសកម្ពុជា. ........ 18
ច្បាប់ថ្មីស្តីពីប្រេងកាត ........ 10
អាជ្ញាធរជាតិប្រេងកាតកម្ពុជា (CNPA) ........ 10
កិច្ចព្រមព្រៀងលើការបែងចែកផលិតផល (PSAs) ........ 11
បទបញ្ញត្តិច្បាប់ទាក់ទងនឹងតម្លាភាពលើប្រាក់ចំណូល និងការត្រួតពិនិត្យផ្នែកថវិកា ........ 11
ការគ្រប់គ្រងចំណូល និងថវិកា ........ 22
កម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ........ 22
វេទិកាសេដ្ឋកិច្ចនៃកម្ពុជា/ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) ........ 23
គំនិតផ្តួចផ្តើមនៃតម្លាភាពឧស្សាហកម្មនិស្សារណកម្ម (EITI) ........ 23

## សេចក្តីផ្តើម

គេបានរកឃើញថា មានប្រេង និងឧស្ម័ននៅក្នុងប្រទេសកម្ពុជា ហើយរដ្ឋាភិបាលបានចេញអាជ្ញាប័ណ្ណខួងរុករកដល់ក្រុមហ៊ុនផលិតប្រេង និងឧស្ម័ននានា។ រដ្ឋាភិបាលបានចង្អុលបង្ហាញថា ផលិតកម្មប្រេង និងឧស្ម័នអាចចាប់ផ្តើមក្នុងឆ្នាំ ២០០៩ ឆាប់ៗនេះ។ ចំណូលបានមកពីប្រេង និងឧស្ម័នសំរាប់ប្រទេសកម្ពុជា ប្រហែលជាមានច្រើន ហើយអាចធ្វើឱ្យជីវភាពរបស់ប្រជាពលរដ្ឋខ្មែរ មានភាពប្រសើរឡើង។ តែទោះជាយ៉ាងណា នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ប្រេង និងឧស្ម័នមិនត្រឹមតែមិនបានផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋទេ ប៉ុន្តែបានធ្វើឱ្យជីវភាពរបស់ពួកគេលំបាកកាន់តែខ្លាំងឡើង។ បាតុភូតនេះ ត្រូវបានគេហៅថា "*បណ្តាសារនៃធនធាន*" ហើយដែលបណ្តាលមកពីអំពើពុករលួយ និងការគ្រប់គ្រងផ្នែកសេដ្ឋកិច្ចមិនបានត្រឹមត្រូវ និងធ្វើឱ្យកាន់តែយ៉ាប់យ៉ឺន ដោយសារកង្វះយន្តការគណនេយ្យភាព។ លើសពីនេះ ផលិតកម្មប្រេង និងឧស្មន័ ដោយអាស្រ័យទៅតាមចរិតនៃសកម្មភាពដែលបានធ្វើឡើង និងថាតើវាធ្វើឡើងនៅក្នុងសមុទ្រ ឬលើផ្ទៃដីគោក អាចជះឥទ្ធិពលយ៉ាងខ្លាំងដល់សង្គម និងបរិស្ថាន។

ឯកសារនេះមានគោលបំណងបង្ហាញជូននូវបញ្ហានានា ដែលអាចកើតឡើងទាក់ទងនឹងប្រេង និងឧស្ម័ននៅក្នុងប្រទេសកម្ពុជា ដើម្បីជួយដល់សង្គមស៊ីវិលឱ្យកំណត់ថាតើពួកគេមានតួនាទីអ្វីខ្លះ ទាក់ទងនឹងវិស័យប្រេង និងឧស្ម័ន តើសកម្មភាពអ្វីខ្លះដែលគេអាចធ្វើនៅក្នុងពេលបច្ចុប្បន្ន ព្រមទាំងជំនាញ ពត៌មាន និងការគាំទ្រអ្វីខ្លះដែលគេត្រូវការ។ ជាដំបូង បញ្ហារួមមួយចំនួននឹងត្រូវបានលើកមកបង្ហាញ ហើយបន្ទាប់មក ស្ថានភាពបច្ចុប្បន្នក្នុងប្រទេសកម្ពុជា នឹងត្រូវលើកមកជជែកនៅពេលបន្ទាប់។ គេទំនងជាត្រូវការការស៊ើបអង្កេត និងជំនួយបច្ចេកទេសបន្ថែមទៀត នៅពេលចូលជ្រៅទៅក្នុងរឿងនេះ។

## ស្ថានភាពទូទៅ[១]

### *ផលិតកម្ម និងការចំរាញ់ប្រេង និងឧស្ម័ន*

ប្រេង និងឧស្ម័នមាននៅក្នុងចន្លោះរន្ធនៅក្នុងថ្មស្ពោត នៅក្រោមដី ឬក្រោមសមុទ្រ ដែលគេហៅថា "*អាង* "។ អាងភាគច្រើនបំផុត មានទាំងប្រេង និងឧស្ម័ន ព្រមទាំងទឹកផងដែរ។ អាងខ្លះមានជំរៅតែប៉ុន្មានរយហ្វីត (1feet=0.3048m) នៅក្រោមផ្ទៃផែនដីប៉ុណ្ណោះ ហើយខ្លះទៀតមានជំរៅជាច្រើនពាន់ហ្វីត។

ប្រេង និងឧស្ម័នគឺជាអ៊ីដ្រូកាបូ ដែលមានន័យថាវាមានធាតុផ្សំពីអ៊ីដ្រូសែន និងកាបូន។ ប្រេងគឺជាអង្គធាតុរាវខាប់ រីឯឧស្ម័នគឺជាឧស្ម័នដែលអាចឆេះបាន។ ប្រេងនៅក្នុងទំរង់ធម្មជាតិរបស់វា ត្រូវគេ

[១] ពត៌មានបច្ចេកទេសពីគេហទំព័ររបស់សមាគមវិស្វករប្រេងកាត http://www.spe.org/spe/jsp/basic/0,,1104_1708,00.html

ហៅថា " *ប្រេងឆៅ* "។ ឧស្ម័ន ជួនកាលត្រូវគេហៅថា " *ឧស្ម័នធម្មជាតិ* "។ " *ប្រេង* " គឺជាពាក្យទូទៅ សំដៅទៅលើប្រេង និងផលិតផលប្រេង។

ការរុករក និងផលិតកម្មប្រេង និងឧស្ម័ន ត្រូវគេហៅថា " *សកម្មភាពដើមខ្សែ* " (Upstream)។ គេជីកប្រេង និងឧស្ម័ន តាមការខួងអណ្ដូងចូលទៅក្នុងអាង។ មិនមានវិធីណាមួយដែលអាចប្រាប់ឱ្យដឹងច្បាស់ថាមានប្រេង និងឧស្ម័ននៅក្នុងតំបន់ជាក់លាក់ណាមួយ មុនការខួងនោះទេ ប៉ុន្តែអ្នកវិទ្យាសាស្ត្រអាចវិភាគទៅលើកំណភូគព្ភសាស្ត្រនៅក្រោមដី ដោយការប្រើប្រាស់រលកសំលេង ( ការស្ទង់ស៊ីស្មិក ) (Seismic surveys ) ដើម្បីឱ្យដឹងថា តើវាមានលក្ខខណ្ឌសមប្រកបសំរាប់ឱ្យមានអាងកំណប្រេង និងឧស្ម័នឬអត់។ បន្ទាប់មក គេក៏ធ្វើការខួងរុករកដើម្បីដឹងថាតើមានប្រេង និងឧស្ម័នឬអត់ រួចមកទើបគេធ្វើការប៉ាន់ស្មានពីបរិមាណ និងវិធីសាស្ត្រសំរាប់ទាញយកប្រេង។ ការខួងអាងប្រេង និងឧស្ម័នមួយចំនួនចំណាយអស់តិច និងមានភាពងាយស្រួល ជាងអាងដទៃទៀត រីឯអាងខ្លះទៀត ទាល់តែមានបច្ចេកវិទ្យាដ៏ទំនើបទើបអាចខួងបាន ហើយក្រុមហ៊ុនផលិតប្រេង និងឧស្ម័នទាំងអស់ មិនសុទ្ធតែមាននោះទេ។

គេអាចទាញប្រេង និងឧស្ម័ន មកខាងក្រៅតាមអណ្ដូង (គេហៅផងដែរថា រន្ធអណ្ដូង ) ដែលគេខួងចូលទៅក្នុងអាង ដែលដំណើរការដោយមានប្រព័ន្ធគំរបបិទបើក និងឧបករណ៍នៅពីលើអណ្ដូង (មាត់អណ្ដូង = wellhead )។នៅពេលចាប់ផ្ដើមបូម ជារឿយៗសម្ពាធនៅក្រោមដីរុញច្រានឱ្យប្រេង និងឧស្ម័ន ឡើងចេញមកខាងក្រៅបានយ៉ាងស្រួល ប៉ុន្តែក្រោយមកវាអាចតំរូវឱ្យមានការបូមឡើង។ អណ្ដូងភាគច្រើនបំផុត មានប្រេង ឧស្ម័ន និងទឹកលាយគ្នា ហើយវត្ថុធាតុទាំងនេះនឹងត្រូវបំបែកចេញពីគ្នានៅលើមាត់អណ្ដូង។

ជាទូទៅ ផលិតកម្មប្រេង និងឧស្ម័ន មានការកើនឡើងពីដំបូងក្នុងរយៈពេលខ្លី ហើយក្រោយមកមានការថយចុះបន្តិចម្ដងៗ ក្នុងរយៈពេលយ៉ាងយូរ។ ការខួងរុករក និងការផលិតប្រេង និងឧស្ម័នត្រូវបានគេហៅថា " *សកម្មភាពដើមខ្សែ* "។

បន្ទាប់ពីបូមចេញពីអណ្ដូង ប្រេងត្រូវបានគេយកចំរាញ់នៅក្នុងរោងចក្រចំរាញ់ ដោយបំប្លែងចេញជាផលិតផលដែលអាចលក់បាន ដូចជាប្រេងសាំង ប្រេងម៉ាស៊ូត ប្រេងយន្តហោះ ជាដើម។ ប្រេងឆៅជាទូទៅ ត្រូវបានបង្ហូរចេញពីឧបករណ៍ញែកវត្ថុធាតុនៅមាត់អណ្ដូង ចូលទៅក្នុងបំពង់តូចៗដែលត្រូវបង្ហូរបន្តចូលទៅក្នុងបំពង់ធំ។ ជារឿយៗ បំពង់ទាំងនោះ ត្រូវបានគេប្រើដើម្បីនាំប្រេងពីក្នុងសមុទ្រមកកាន់ច្រាំង។ បំពង់បង្ហូរ អាចបញ្ជូនប្រេងពីកន្លែងផលិត ទៅកន្លែងស្តុកទុក ដើម្បីដឹកជញ្ជូនចេញ។ គេក៏អាចប្រើបំពង់ដើម្បីបង្ហូរប្រេងពីតំបន់កំពង់ផែទៅកាន់រោងចក្រចំរាញ់ និងចេញពីរោងចក្រចំរាញ់ ទៅមណ្ឌលចែកចាយបានដែរ។ ចេញពីមណ្ឌលចែកចាយនោះ ជាទូទៅប្រេងត្រូវបានដឹកតាមរថយន្តដឹកប្រេងទៅកាន់

ទីកន្លែងលក់រាយ (ជាឧទាហរណ៍ ដូចជាស្ថានីយ៍ប្រេងឥន្ទនៈជាដើម)។ ការចំរាញ់ ការចែកចាយ និង ការលក់ ត្រូវបានគេហៅថា " *សកម្មភាពចុងខ្សែ* " ( Downstream )។

ឧស្ម័នធម្មជាតិ ដែលយកទៅប្រើសំរាប់ការចំអិន និងកំដៅ មានការពិបាកក្នុងការដឹកជញ្ជូន ផ្លូវឆ្ងាយ ដែលហេតុនេះ ក្នុងប្រទេសភាគច្រើន ឧស្ម័នត្រូវបានគេប្រើប្រាស់តែនៅក្នុងប្រទេស ឬនាំចេញ ទៅប្រទេសជិតខាង តាមបំពង់បង្ហូរតែប៉ុណ្ណោះ។ មានបច្ចេកវិទ្យាសំរាប់ពង្រាវឧស្ម័នធម្មជាតិ ឱ្យទៅជា វត្ថុធាតុរាវ ដើម្បីងាយស្រួលដឹកជញ្ជូនតាមស៊ីទែនដូចជាប្រេងដែរ តែការបម្លែងរបៀបនេះ នៅមានកំរិត នៅឡើយ នាពេលបច្ចុប្បន្ន។

### *ក្រុមហ៊ុនប្រេង និងឧស្ម័ន*

ប្រេង និងឧស្ម័នគឺជាធនធានធម្មជាតិ ហើយជាទូទៅ វាជាកម្មសិទ្ធិរបស់ប្រទេស ដែលមានដែនដី គ្របដណ្តប់លើអាងទាំងនោះ (ប្រទេសម្ចាស់ផ្ទះ) ទោះបីជាថា បើសិនជាប្រេង និងឧស្ម័ននោះនៅក្រោម ដីអ្នកណា ប្រេង និងឧស្ម័នអាចជាកម្មសិទ្ធិរបស់ម្ចាស់ដីនោះ ក៏ដោយចុះ។ ការណ៍នេះ ទាក់ទងនឹង បញ្ញត្តិច្បាប់របស់ប្រទេសជាម្ចាស់ផ្ទះ។

ប្រទេសជាម្ចាស់ផ្ទះចេញអាជ្ញាប័ណ្ណឱ្យក្រុមហ៊ុនផលិតប្រេង និងឧស្ម័ន ដើម្បីរុករកប្រេង និង ឧស្ម័នហើយទាញយកធនធានទាំងនោះ។ ជាថ្នូរមកវិញ ក្រុមហ៊ុនត្រូវបង់ថ្លៃឈ្នួល ឬចែកគ្នាលើចំណែក ប្រេង និង ឧស្ម័នដែលផលិតបាន។

មានក្រុមហ៊ុនផលិតប្រេង និងឧស្ម័នមិនច្រើនឡើយនៅលើពិភពលោក។ ដោយសារតែការធ្វើ វិនិយោគក្នុងវិស័យ ប្រេង និងឧស្ម័ននេះតម្រូវឱ្យមានដើមទុនច្រើន ក្រុមហ៊ុនភាគច្រើន មានទំហំធំៗ ណាស់ (ជារឿយៗ គឺជាលទ្ធផលនៃការច្របាច់បញ្ចូលគ្នារវាងក្រុមហ៊ុនដែលធំស្រាប់រួចទៅហើយ) និង មានប្រតិបត្តិការនៅទូទាំងពិភពលោក។ ជារឿយៗ ក្រុមហ៊ុនទាំង នោះមានរោងចក្រចំរាញ់ ឬ មធ្យោបាយកែច្នៃផ្សេងៗទៀត ហើយក៏ជាម្ចាស់បណ្តាញចែកចាយ និងលក់រាយផងដែរ។ តាមពិតទៅ ការដែលហៅក្រុមហ៊ុនទាំងនោះ ថាជាក្រុមហ៊ុន គឺមិនត្រឹមត្រូវឡើយ ពីព្រោះពួកគេជាក្រុមនៃក្រុមហ៊ុន ដែលបានច្របាច់ចូលគ្នានៅប្រទេសផ្សេងៗគ្នា ប៉ុន្តែត្រូវគ្រប់គ្រងរួមដោយក្រុមហ៊ុនមេមួយ។ ប្រទេស ដែលក្រុមហ៊ុនបានមានទីតាំងការិយាល័យកណ្តាល ត្រូវបានគេកំណត់ថាជា " *សញ្ជាតិ* " របស់ក្រុមនោះ។ ក្រុមហ៊ុនប្រេងធំៗ នៅប្រទេសអភិវឌ្ឍន៍ រួមមាន:

- ក្រុមហ៊ុនសែល — អង់គ្លេស និងហូឡង់ (Shell – UK/Holland )
- ប៊ីភី — អង់គ្លេស ( BP – UK )
- ឆេវរ៉ុន/តិកសាកូ - សហរដ្ឋអាមេរិក (Chevron/Texaco – USA)

- អ៊ិចសុន / ម៉ូប៊ីល - សហរដ្ឋអាមេរិក (Exxon/Mobil – USA)
- តូតាល់/ អេលហ្វ៍ - បារាំង (Total/Elf – France)

ឥឡូវនេះក៏មានក្រុមហ៊ុនផលិតប្រេង និងឧស្ម័នអាស៊ីជាច្រើនដែរ ហើយដែលក្នុងនោះមួយចំនួនជាក្រុមហ៊ុនរដ្ឋ។ កាលពីមុន ក្រុមហ៊ុនទាំងនោះមានជំនាញ និងបច្ចេកទេសអន់ថយជាងក្រុមហ៊ុនប្រទេសអភិវឌ្ឍន៍ ដែលការណ៍នេះធ្វើឱ្យលទ្ធភាពរបស់គេមានកំរិត ដើម្បីធ្វើអាជីវកម្មនៅឯអណ្តូងមួយចំនួន ប៉ុន្តែករណីនេះ លែងជាបញ្ហាចោទតទៀតហើយសំរាប់ក្រុមហ៊ុននៅអាស៊ីនាពេលបច្ចុប្បន្ននេះ។ ក្រុមហ៊ុនប្រេងអាស៊ីធំៗរួមមានៈ

- ភីធីធី - ថៃ (PTT – Thailand)
- ប៉េត្រូណាស់ - ម៉ាឡេស៊ី (Petronas – Malaysia)
- សាជីវកម្មប្រេងជាតិក្នុងសមុទ្ររបស់ចិន (CNOOC - China/Hong Kong )

ផលិតកម្មប្រេង និងឧស្ម័ន ជារឿយៗផ្តល់ហិរញ្ញប្បទានដោយសហាគមក្រុមហ៊ុន (Consortium of Companies) ដែលបានបរិច្ចាគទុន ហើយទទួលបាននូវចំណែក ឬផលចំណេញ តាមសមាមាត្រដែលបានព្រមព្រៀងគ្នា។ ការដាក់ចូលដើមទុនរួមគ្នារបៀបនេះគេហៅថា " *ក្រុមហ៊ុនរកស៊ីរួមគ្នា* " ហើយ "*ក្រុមហ៊ុនរកស៊ីរួមគ្នា*" ដោយឡែកមួយ អាចត្រូវបានបង្កើតឡើងសំរាប់គំរោងមួយ ដែលពួកគេទាំងអស់មានភាគហ៊ុន។ ក្នុងករណីខ្លះ រដ្ឋាភិបាលនៃប្រទេសម្ចាស់ផ្ទះក៏ជាសមាជិក នៃសហាគមនេះដែរ។ ជាទូទៅក្រុមហ៊ុនមួយមានការទទួលខុសត្រូវសំរាប់ប្រតិបត្តិការផលិតផលជាក់លាក់មួយ (ក្រុមហ៊ុនប្រតិបត្តិ ឬករី) ដោយក្រុមហ៊ុនដទៃទៀតដើរតួនាទីអកម្ម។ ក្រុមហ៊ុនប្រតិបត្តិ ជារឿយៗគឺជាអ្នកដែលមានភាគហ៊ុនច្រើនជាងគេ ប៉ុន្តែមិនមែនជានិច្ចជាកាលនោះទេ។

តំលៃសំរាប់ការខួងអណ្តូងរុករក និងសាងសង់ជើងខួងអណ្តូង ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ដទៃទៀត មានតម្លៃខ្ពស់ណាស់ ហើយផលិតកម្មប្រេង និងឧស្ម័នត្រូវបន្តអស់រយៈពេលជាច្រើនឆ្នាំ។ ដូចនេះហើយ បានជាក្រុមហ៊ុនរំពឹងទុកថា ត្រូវដាក់ទីតាំង និងធ្វើទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេសជាម្ចាស់ផ្ទះ ក្នុងរយៈពេលមួយយូរអង្វែង។

ក្រុមហ៊ុនប្រេង និងឧស្ម័នយល់ព្រមផលិតប្រេង និងឧស្ម័ន តែក្នុងករណីដែលកិច្ចសន្យាពាណិជ្ជកម្មដែលខ្លួនបានព្រមព្រៀងជាមួយប្រទេសម្ចាស់ផ្ទះ ផ្តល់ប្រយោជន៍គ្រប់គ្រាន់សំរាប់ក្រុមហ៊ុន និងលុះត្រាតែគំរោងនេះបានជោគជ័យ ដើម្បីទូទាត់នឹងការដែលក្រុមហ៊ុនប្រថុយនឹងការខាតបង់។ ក្រុមហ៊ុនត្រូវតែធ្វើការប៉ាន់ប្រមាណ ថាតើផលចំណេញដែលនឹងបានពីការទាញយកប្រេងនោះ គ្រប់គ្រាន់សំរាប់ការចំណាយដែលនឹងមានឬទេ ដែលជាទូទៅជាចំណាយខ្ពស់។ ក្រុមហ៊ុនត្រូវតែប្រថុយ មិនត្រឹមតែនឹង

បរិមាណប្រេង និងឧស្ម័នដែលនឹងផលិតបាន ព្រមទាំងតំលៃក្នុងការបូមប៉ុណ្ណោះទេ ប៉ុន្តែក្រុមហ៊ុនក៏ត្រូវប្រថុយនឹងបញ្ហានានាហួសពីការគ្រប់គ្រងរបស់ខ្លួន ដែលប៉ះពាល់ដល់ប្រាក់ចំណេញរបស់ខ្លួនដែរ ដូចជាតំលៃប្រេង និងឧស្ម័នក្នុងទីផ្សារលើពិភពលោក និងបញ្ហាដែលនាំទៅដល់ការបញ្ឈប់ផលិតកម្ម ដូចជាស្ថិរភាពរបស់រដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះ ចេតនា ឬបំណងល្អរបស់រដ្ឋាភិបាល (ដូចជា មិនរឹបអូសយកឧបករណ៍, កែប្រែច្បាប់ ដូចជារបបពន្ធអាករ, ឬមិនគោរព ឬបង្ខំឱ្យចរចារឡើងវិញពីលក្ខខណ្ឌនៃអាជ្ញាប័ណ្ណផលិតប្រេង និងឧស្ម័នជាដើម) ព្រមទាំងសុវត្ថិភាពចំពោះទីតាំង ដែលមាននៅក្នុងប្រទេសម្ចាស់ផ្ទះផងដែរ។

ក្រុមហ៊ុនប្រេង និងឧស្ម័នមានសក្តានុពលក្នុងការដើរតួនាទីវិជ្ជមាននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ទោះបីជាក្រុមហ៊ុនជាច្រើនផ្តោតតែទៅលើការរកចំណេញ ដែលជាមុខងារចម្បងរបស់ខ្លួនក៏ដោយ ក្រុមហ៊ុនប្រេង និងឧស្ម័នធំៗជាច្រើន មានកម្មវិធីវិនិយោគផ្នែកសង្គមគួរឱ្យកត់សំគាល់ ដែលជាផ្នែកនៃសកម្មភាពផលិតកម្មរបស់ខ្លួននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ហើយពួកគេក៏អាចចូលរួមក្នុងការពង្រឹងជំនាញ និងសមត្ថភាពដ៏មានតំលៃផងដែរ។ ក្រុមហ៊ុនផលិតប្រេង និងឧស្ម័នមួយចំនួន គឺជាអ្នកដឹកនាំពិភពលោកនៅក្នុងការទទួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន ( Corporate Social Responsibility) ហើយអាចមានលទ្ធភាពដាក់ឥទ្ធិពលលើដំណើរប្រតិបត្តិការរបស់ក្រុមហ៊ុនប្រេង និងឧស្ម័ន និងសហគមន៍ពាណិជ្ជកម្មនៅក្នុងស្រុកដទៃទៀត។ សង្គមស៊ីវិលមានតួនាទីក្នុងការលើកទឹកចិត្ត និងរក្សានូវសម្ពាធលើក្រុមហ៊ុនឱ្យគោរពតាមបទដ្ឋានខ្ពស់ និងចូលរួមចំណែកអភិវឌ្ឍប្រទេសជាម្ចាស់ផ្ទះ។

ក្រុមហ៊ុនប្រេង និងឧស្ម័នក៏ដើរតួនាទីគាំទ្រផងដែរ ទាក់ទងនឹងគោលនយោបាយ និងកំណែទម្រង់។ ឧទាហរណ៍ក្រុមហ៊ុនផលិតប្រេង និងឧស្ម័នមួយចំនួន រួមទាំង Chevron Texaco ផង គឺជាអ្នកគាំទ្រដល់ *គំនិតផ្តួចផ្តើមពីតម្លាភាពនៃឧស្សាហកម្មនិស្សារណកម្ម* (Extractive Industry Transparency Initiatives = EITI) (សូមអានផ្នែកខាងក្រោម)។ ក្រុមហ៊ុនទាំងនោះ អាចគាំទ្រដល់ការបង្កើតច្បាប់ និងពង្រឹងសមត្ថភាពដល់ភ្នាក់ងាររដ្ឋាភិបាល ទាក់ទងនឹងតម្លាភាព និងការគ្រប់គ្រងចំណូលពីប្រេង និងឧស្ម័ន។ ទោះជាយ៉ាងក៏ដោយ ពុំមានភាពប្រាកដប្រជា ដើម្បីរំពឹងថា ក្រុមហ៊ុនប្រេង និងឧស្ម័នទាំងឡាយធ្វើសកម្មភាពជាឯកតោភាគីឡើយ និងថាតើក្រុមហ៊ុន ទាំងនោះអាច ឬនឹងធ្វើការបញ្ចុះបញ្ចូលរដ្ឋាភិបាលយ៉ាងដូចម្តេច លើបញ្ហាវិវាទណាមួយដូបម្តេចឡើយ។ ការណ៍នេះគឺនឹងអាស្រ័យទៅនឹង ថាតើក្រុមហ៊ុនទាំងនោះមានជំហររឹងមាំប៉ុណ្ណានៅក្នុងប្រទេសនោះ ក៏ដូចជាទាក់ទងទៅនឹងគូរប្រជែងរបស់គេ ដែលអាចមិនមានមិនខ្វល់ទាល់តែសោះជាមួយបញ្ហាទាំងនេះ។

***បញ្ហាច្បាប់***

កាតព្វកិច្ចផ្លូវច្បាប់ជាមូលដ្ឋាន រវាងប្រទេសម្ចាស់ផ្ទះជាមួយក្រុមហ៊ុនផលិតប្រេង និងឧស្ម័ន មានដូចខាងក្រោម:

- ប្រទេសជាម្ចាស់ផ្ទះផ្តល់ឱ្យក្រុមហ៊ុននូវអាជ្ញាប័ណ្ណផ្តាច់មុខដើម្បីជីកប្រេង និងឧស្ម័ន នៅក្នុងតំបន់ដែលបានកំណត់ ។
- ប្រទេសជាម្ចាស់ផ្ទះកំណត់បទបញ្ញត្តិ ថាតើក្រុមហ៊ុនអាចប្រតិបត្តិការរុករកប្រេងរបស់ខ្លួនយ៉ាងដូចម្តេចខ្លះ ដោយរាប់បញ្ចូលទាំងការបញ្ឈប់ប្រតិបត្តិការ និងមានអំណាចអធិការកិច្ច និងដាក់ទណ្ឌកម្ម នៅពេលដែលមានការរំលោភ។
- អាចមានប្រាក់រង្វាន់ត្រូវបង់ផ្សេងៗដែលក្រុមហ៊ុនបង់ឱ្យរដ្ឋាភិបាល ដូចជាប្រាក់រង្វាន់សំរាប់ការចុះហត្ថលេខាផ្តល់អាជ្ញាប័ណ្ណ ឬប្រាក់រង្វាន់ផលិតកម្ម។ ប្រាក់រង្វាន់ទាំងនេះហាក់ដូចជាតិចតួចបើធៀបទៅនឹងប្រាក់បង្វិលសរុប ហើយអាចទាមទារមកវិញជាចំណាយនៅពេលណាមួយនាពេលអនាគត (សូមមើលខាងក្រោម)។
- ប្រទេសម្ចាស់ផ្ទះទទួលបាននូវថ្លៃសួយសារ ពីក្រុមហ៊ុន សំរាប់ប្រេង និងឧស្ម័នដែលក្រុមហ៊ុនបានលក់ ហើយជាទូទៅគឺគិតទៅតាមភាគរយនៃតំលៃលក់។
- ភាគរយនៃប្រេង និងឧស្ម័នដែលផលិតបាន អាចត្រូវបានលៃទុកទុកសំរាប់ទូទាត់ចំណាយរបស់ក្រុមហ៊ុននៅក្នុងផលិតកម្មប្រេង និងឧស្ម័ន ពោលគឺសំរាប់ផលិតកម្មទាំងមូល ឬតាមផ្នែក។
- ប្រេង និងឧស្ម័នដែលនៅសល់ ត្រូវចែកគ្នារវាងក្រុមហ៊ុន និងប្រទេសម្ចាស់ផ្ទះ។ ប្រទេសម្ចាស់ផ្ទះអាចលក់ចំណែករបស់ខ្លួន ចំរាញ់វាបើសិនជាមានរោងចក្រចំរាញ់ ឬជួលឱ្យគេចំរាញ់ ហើយលក់វា ឬទុកប្រើប្រាស់ខ្លួនឯងទាំងអស់ ឬមួយផ្នែក។
- ប្រទេសម្ចាស់ផ្ទះ យកពន្ធពីក្រុមហ៊ុនលើប្រាក់ចំណូលសុទ្ធ ពីលើការផលិតប្រេង និងឧស្ម័នទៅតាមអត្រាដែលបានព្រមព្រៀងគ្នា។

លក្ខខណ្ឌទាំងនេះ ជាទូទៅមានចែងនៅក្នុងបណ្តុំនៃបញ្ញត្តិច្បាប់មួយ ដែលត្រូវអនុវត្តចំពោះក្រុមហ៊ុនចំរាញ់ប្រេង និងឧស្ម័នទាំងអស់ និងជាឯកសារសាធារណៈ ហើយនៅក្នុងកិច្ចសន្យា (ជារឿយៗហៅថាកិច្ចព្រមព្រៀងបែងចែកផលិតផល) ជាមួយក្រុមហ៊ុននីមួយៗ លក្ខខណ្ឌទាំងនោះអាចខុសគ្នា និងអាចជាការសម្ងាត់។ ជារឿយៗ មានគំរូសំរាប់កិច្ចព្រមព្រៀងបែងចែកផលិតផលនេះ នៅក្នុងច្បាប់ស្តីពីប្រេងកាត ដើម្បីធ្វើម៉េចឱ្យមានរចនាសម្ព័ន្ធ និងធាតុជាមូលដ្ឋានដូចគ្នា ទោះបីជាលក្ខខណ្ឌនៃការរៀបចំជា មួយក្រុមហ៊ុននីមួយៗអាចខុសគ្នាក៏ដោយ។

### *បណ្តាសាធនធាន*[២]

ផ្ទុយពីការរំពឹងទុក ការរកឃើញនូវកំណប់ដ៏ធំនៃធនធានធម្មជាតិ ដូចជាប្រេង និងឧស្ម័ន នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ មិនបាននាំឱ្យមានការរីកចំរើនផ្នែកសេដ្ឋកិច្ច ឬសង្គមឡើយ។ នៅក្នុងប្រទេសមួយចំនួន ដូចជាប្រទេសនីហ្សេរីយ៉ា និងប្រទេសវ៉េណេហ្ស៊ូអេឡា ជាដើម ប្រជាពលរដ្ឋទូទៅមានជីវិភាពកាន់តែលំបាក បន្ទាប់ពីទទួលបានចំណូលពីប្រេងក្នុងអំឡុងពេល ៣០ ឆ្នាំមក ។

បញ្ហានេះមានមូលហេតុខុសៗគ្នា។ ជាការងាយយល់បំផុតនោះគឺ នៅក្នុងប្រទេសដែលមានអំពើពុករលួយរីករាលដាល ហើយគ្មានគណនេយ្យភាព និងនីតិរដ្ឋនោះ ចំណូលមួយភាគធំត្រូវបានបង្វែរដោយងាយទៅក្នុងហោប៉ៅមន្ត្រីរដ្ឋាភិបាល សំរាប់ប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួន។

ទោះជាយ៉ាងនេះក្តី កត្តាសេដ្ឋកិច្ច និងនយោបាយដ៏ស្មុគស្មាញ ក៏អាចរួមចំណែកនៅក្នុងបញ្ហានេះផងដែរ។

- ចំណូលនេះអាចធ្វើឱ្យអត្រាប្តូរប្រាក់មានការឡើងថ្លៃ ដែលធ្វើឱ្យវិស័យកសិកម្ម និងកម្មន្តសាលក្នុងស្រុកកាន់តែលំបាកក្នុងការប្រកួតប្រជែងជាមួយនឹងផលិតផលនាំចូល និងទីផ្សារនាំចេញ ដែលការណ៍នេះអាចរារាំងដល់ការអភិវឌ្ឍន៍រយៈពេលវែង និងការជួយស្រោចស្រង់វិស័យទាំងនេះផង។
- ចំណូលនេះមិនស្ថិតស្ថេរឡើយ ដោយសារវាអាស្រ័យលើការប្រែប្រួលនៃតំលៃប្រេង និងឧស្ម័ននៅលើទីផ្សារ។ លើសពីនេះ ប្រសិនបើរដ្ឋាភិបាលមិនបានរៀបផែនការសំរាប់ការធ្លាក់ចុះនៃចំណូលនេះទេ រដ្ឋាភិបាលអាចត្រូវការខ្ចីបុលដើម្បីដោះស្រាយកង្វះខាត ដែលអាចនាំទៅដល់ការជំពាក់បំណុលច្រើន ឬការបោះពុម្ពលុយថែម និងនាំឱ្យមានអតិផរណាខ្ពស់។ ម្យ៉ាងវិញទៀត បើមានការកាត់បន្ថយចំណាយភ្លាមៗ វាក៏អាចបង្កផលប៉ះពាល់យ៉ាងខ្លាំងដល់វិស័យឯកជន ផងដែរ។
- រដ្ឋាភិបាលដែលពឹងផ្អែកលើចំណូលពីប្រេង និងឧស្ម័ន អាចមិនសូវមានការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ ដោយសារតែចំណូលនេះវាមិនអាស្រ័យលើអ្នកបង់ពន្ធឡើយ ហើយប្រជាពលរដ្ឋក៏មិនសូវចាប់អារម្មណ៍ចំពោះសកម្មភាពរបស់រដ្ឋាភិបាលដែរ។ ចំណូលពីប្រេងនិងឧស្ម័នធ្វើឱ្យរដ្ឋាភិបាលឯករាជ្យយ៉ាងខ្លាំង។នៅក្នុងសង្គមធម្មតា រដ្ឋាភិបាលត្រូវទទួលបាននូវការយល់ព្រម (ឬយ៉ាងហោចណាស់ ក៏ជាកិច្ចព្រមព្រៀងការងារ) ជាមួយសង្គម ដើម្បី

[២] សូមអានទំព័រទី ៨ ស្តីពី " *ការវិភាគ SWOT សំរាប់សេដ្ឋកិច្ចកម្ពុជា* " ខែធ្នូ ឆ្នាំ ២០០៥ ដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ/ហាវើត សំរាប់វេទិកាស្តីពីសេដ្ឋកិច្ចកម្ពុជា ថ្ងៃទី ១៧ មករា ២០០៦។ សូមអានផងដែរ នូវកំណត់សង្ខេបទី៧របស់ ODI " *ការបង្វែរពីបណ្តាសា* " ដោយបណ្ឌិត M. Warner ។

ប្រមូលពន្ធសំរាប់ផ្តល់ហិរញ្ញប្បទានដល់ប្រតិបត្តិការរបស់រដ្ឋាភិបាល។ ផ្ទុយមកវិញ កាលណាភាគច្រើននៃប្រភពថវិការបស់ខ្លួនបានមកពីចំណូលពីប្រេង និងឧស្ម័ននោះ រដ្ឋាភិបាលមិនសូវជាត្រូវការឱ្យមានការយល់ព្រមបែបនេះឡើយ ហើយរដ្ឋាភិបាលក៏មិនសូវមានការទទួលខុសត្រូវចំពោះសង្គម នូវលទ្ធផលរបស់ខ្លួនបានធ្វើដែរ។

បញ្ហាទាំងនេះស្តែងឡើងតាមរបៀបផ្សេងៗគ្នា ដោយអាស្រ័យទៅលើស្ថានភាពនយោបាយ និងសេដ្ឋកិច្ចនៅក្នុងប្រទេសជាក់លាក់ណាមួយ ហើយក៏មិនមានរូបមន្តណាសំរាប់ជៀសវាងបណ្តាសាធនធាននេះដែរ។ ក៏ប៉ុន្តែ មានបញ្ហាជាមូលដ្ឋានចំនួនពីរដែលត្រូវដោះស្រាយ:

- *តម្លាភាព :* ការបើកចំហពីចំនួន ពេលវេលា និងច្រកសំរាប់ទទួលចំណូល ដោយធ្វើយ៉ាងណាឱ្យភាគីខាងក្រៅរដ្ឋាភិបាលអាចត្រួតពិនិត្យបាន ដើម្បីធានាថាមិនមានការបន្លែបន្លំខុសច្បាប់ និងផ្តល់ឱ្យប្រជាពលរដ្ឋនូវពត៌មានជាមូលដ្ឋាន ដើម្បីពិនិត្យមើលការគ្រប់គ្រង និងប្រើប្រាស់ថវិកានោះឱ្យត្រឹមត្រូវ។
- *ការគ្រប់គ្រងចំណូល :* ការធ្វើសេចក្តីសំរេចចិត្តប្រកបដោយការយល់ដឹង និងដោយប្រុងប្រយ័ត្ន អំពីការគ្រប់គ្រងថវិកា និងការប្រើប្រាស់ចុងក្រោយនូវថវិកា។

ដំណោះស្រាយអាចមានការជាន់គ្នាខ្លះ។ ជាឧទាហរណ៍ យន្តការមួយនៃយន្តការរួមជាច្រើនដែលគេយកមកប្រើ គឺទុកចំណូលដែលបានមកពីប្រេង ឬផ្នែកខ្លះនៃចំណូលនេះទៅក្នុងមូលនិធិប្រេងដាច់ដោយឡែកមួយដែលជួយឱ្យមានតម្លាភាព និងការគ្រប់គ្រងហ្មត់ចត់។ (ទោះបីជាអ្នកជំទាស់នឹងការទុកដាច់ដោយឡែកនៃចំណូលនេះជឿជថា ចំណូលបានពីប្រេង និងឧស្ម័ន គួរយកទៅប្រើដូចជាផ្នែកផ្សេងៗទៀតនៃចំណូលថវិការដ្ឋ ស្របទៅតាមគោលនយោបាយថវិកា និងសារពើពន្ធដ៏ត្រឹមត្រូវ ក៏ដោយ[៣])។

ប្រទេសនីមួយៗមានកាលទេសៈ តម្រូវការ និងអាទិភាពរៀងៗខ្លួនដែលកំណត់ ថាតើចំណូលពីប្រេង និងឧស្ម័នគប្បីប្រើប្រាស់ទៅលើអ្វីខ្លះ ប្រើប្រាស់យ៉ាងដូចម្តេច និងប្រើប្រាស់នៅពេលណា។ ក៏ប៉ុន្តែបញ្ហាដែលលេចឡើងជាទូទៅគឺ ថាតើថវិកានេះត្រូវយកទៅប្រើយកផលប្រយោជន៍ចាំបាច់សំរាប់សង្គម ឬសំរាប់ការវិនិយោគ (រូបី ឬអរូបី) នៅពេលអនាគត។ (ការណ៍នេះជួនកាលគេហៅថាជា *សមធម៌អន្តរជំនាន់*)។

[៣] កំណត់សង្ខេបលេខ ៧ របស់ ODI (Dr. M. Warner) “ បង្វែរបណ្តាសា : *គោលការណ៍៥យ៉ាង សំរាប់យកជ័យជំនះលើបណ្តាសាធនធានធម្មជាតិ* ” ។

### *គំនិតផ្តួចផ្តើមនៃតម្លាភាពឧស្សាហកម្មនិស្សារណកម្ម (EITI)*

គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម (EITI)[4] គឺជាគំនិតផ្តួចផ្តើមមួយដែលគាំទ្រដោយក្រុមប្រទេស ក្រុមហ៊ុន និងអង្គការសង្គមស៊ីវិលនានា។ គំនិតផ្តួចផ្តើមនេះ មានគោលបំណងជួយដល់រដ្ឋាភិបាលឱ្យទទួលបានទូវតម្លាភាព ទាក់ទងនឹងចំណូលដែលបានមកពីប្រេង ឧស្ម័ន និងរ៉ែ (និស្សារណកម្ម)។ គំនិតផ្តួចផ្តើមនេះ មានលក្ខណៈស្ម័គ្រចិត្ត និងទាមទារឱ្យមានឆន្ទៈនយោបាយពីសំណាក់រដ្ឋាភិបាលដើម្បីអនុវត្ត។ EITI មិនមែនដោះស្រាយគ្រប់បញ្ហាសេដ្ឋកិច្ច និងនយោបាយ ទាក់ទងនឹងចំណូលពីប្រេង និងឧស្ម័នឡើយ។

EITI បានបង្កើតជាសេចក្តីថ្លែងការណ៍ស្តីពីគោលការណ៍មួយ ទាក់ទងនឹងតម្លាភាព ដែលរដ្ឋាភិបាលអាចអនុម័តយកបាន។ គោលការណ៍ទាំងនេះ មានលក្ខណៈទូទៅច្រើន។ អ្វីដែលជាក់លាក់ជាងនេះទៅទៀតគឺថា គោលការណ៍ទាំងនេះក៏បានកំណត់នូវលក្ខណៈវិនិច្ឆ័យ និងឯកសារគោលមួយដែលជាក្របខណ្ឌ និងឯកសារយោង សំរាប់ការអនុវត្តដោយប្រទេសនានាស្តីពីតម្លាភាពលើចំណាយ និងចំណូលពីវិស័យនិស្សារណកម្មនេះ។គោលការណ៍ទាំងនេះរួមមាន សេចក្តីថ្លែងការណ៍ដែលទទួលស្គាល់ថា អ្នកពាក់ព័ន្ធទាំងអស់មានការចូលរួមចំណែក ទាក់ទងនឹងតម្លាភាព និងចំណូល ដោយរាប់បញ្ចូលទាំងអង្គការមិនមែនរដ្ឋាភិបាលផងដែរ។

លក្ខណៈវិនិច្ឆ័យចែងថា គួរមានការបោះពុម្ពផ្សាយទៀងទាត់នូវទឹកប្រាក់ដែលក្រុមហ៊ុនបង់ឱ្យរដ្ឋាភិបាល ហើយការបោះពុម្ពផ្សាយនោះគប្បីមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងអាចយល់បាន ព្រមទាំងងាយស្រួលរក ។ លក្ខណៈវិនិច្ឆ័យនោះក៏ចែងដែរថា ចំណូលគប្បីត្រូវបានធ្វើសវនកម្ម និងផ្ទៀងផ្ទាត់ដោយឯករាជ្យ ហើយថាសង្គមស៊ីវិលគប្បីចូលរួមយ៉ាងសកម្មក្នុងការរៀបចំ ត្រួតពិនិត្យ និងវាយតំលៃដំណើរការនេះ។ រដ្ឋាភិបាលគប្បីបង្កើតផែនការការងារសាធារណៈមួយ សំរាប់អនុវត្តតាម EITI ដែលក្នុងនោះរួមទាំងក្រុមគោលដៅដែលអាចវាស់វែងបាន, ពេលវេលា និងការប៉ាន់ប្រមាណពីឧបសគ្គខាងសមត្ថភាពផងដែរ។

EITI និងអ្នកគាំទ្រ ផ្តល់បច្ចេកទេសទាក់ទងនឹងការអនុវត្ត ទោះបីជា EITI បញ្ជាក់ថាគឺជាការងាររបស់រដ្ឋាភិបាលដើម្បីអនុវត្តក៏ដោយ។ អង្គការមិនមែនរដ្ឋាភិបាលដែលជាគាំទ្រ រួមមាន:

- ភ្នាក់ងារកាតូលិកសំរាប់ការអភិវឌ្ឍន៍ក្រៅប្រទេស (Cafod)
- អង្គការឃ្លាំមើលប្រាក់ចំណូលចចចៀ (Georgia Revenue Watch) និងសម្ព័ន្ធភាពអង្គការមិនមែនរដ្ឋាភិបាលសំរាប់ "តម្លាភាពហិរញ្ញវត្ថុសាធារណៈ"។

---

[៤] www.eitransparency.org

- អង្គការគ្លូបលវីតណេស (Global Witness)
- វិទ្យាស្ថានសង្គមបើកចំហ (Open Society Institute)
- សម្ព័ន្ធភាព បោះពុម្ពអ្វីដែលអ្នកបានបង់ (Publish What You Pay Coalition)
- វិទ្យាស្ថានឃ្លាំមើលចំណូល (Revenue Watch Institute)
- អង្គការតម្លាភាពអន្តរជាតិ (Transparency International)

### ***ការប្រើប្រាស់ប្រេង និងឧស្ម័ន***

មានបញ្ហាមួយចំនួនដែលត្រូវពិចារណាផងដែរ ជុំវិញការប្រើប្រាស់ និងការគ្រប់គ្រងប្រេង និងឧស្ម័ន ហើយផ្នែកនេះនៃអត្ថបទ គ្រាន់តែពន្យល់បញ្ហាទាំងនេះដោយសង្ខេបប៉ុណ្ណោះ។ គេអាចពិចារណាថាតើវាមានប្រយោជន៍សំរាប់ប្រទេសដែរឬទេ ក្នុងការកសាងរោងចក្រចំរាញ់ប្រេងផ្ទាល់ខ្លួនដើម្បីចំរាញ់ប្រេងឆៅ ព្រមទាំងលក់វាសំរាប់ការប្រើប្រាស់ក្នុងប្រទេស។ ក៏ដូចជាផលប្រយោជន៍ខាងសេដ្ឋកិច្ចដែរអាចមានបញ្ហាទាក់ទងនឹងសន្តិសុខប្រេង ដើម្បីធ្វើយ៉ាងណាកុំឱ្យប្រទេសនោះពឹងផ្អែកទាំងស្រុង លើប្រទេសដទៃ សំរាប់ការផ្គត់ផ្គង់ប្រេងដែលចាំបាច់ប្រើប្រាស់។ ការផ្គត់ផ្គង់ឥន្ធនៈក្នុងស្រុកក្នុងតំលៃទាបអាចធ្វើឱ្យមានការចាប់អារម្មណ៍ បើទោះជាអាចមានអំណះអំណាងខាងសេដ្ឋកិច្ចប្រឆាំងនឹងវិធីនេះ ឬវិធីដទៃទៀត ដើម្បីឱ្យប្រេងមានតំលៃកាន់តែទាបក៏ដោយ។ ក៏នៅមានសំណួរផងដែរថា តើនឹងមានអ្វីកើតឡើងចំពោះឧស្ម័នធម្មជាតិ ដោយសារពិបាកក្នុងការដឹកជញ្ជូននោះ។

### ***ផលប៉ះពាល់លើបរិស្ថាន និងសង្គម***

មានឧទាហរណ៍ពីប្រទេសផ្សេងៗ អំពីផលប៉ះពាល់យ៉ាងគ្រោះថ្នាក់ដល់បរិស្ថាន និងសង្គម ដោយសារផលិតកម្មប្រេង និងឧស្ម័ន។ មានការចូលរួមយ៉ាងសកម្មរបស់អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិមួយចំនួន នៅក្នុងសកម្មភាពទាំងនេះ ហើយការចូលរួមនោះគឺសំដៅទៅលើក្រុមហ៊ុនដែលពាក់ព័ន្ធ (ជារឿយៗធ្វើឡើងនៅក្នុងប្រទេសកំណើតរបស់គេ) ក៏ដូចជារដ្ឋាភិបាលផងដែរ។

គ្មានមធ្យោបាយណាដែលសន្មតថាបញ្ហាទាំងនេះនឹងកើតឡើងនៅក្នុងប្រទេសកម្ពុជា ដែលមានលក្ខខណ្ឌសកម្មភាពផលិត ក៏ដូចជាលក្ខខណ្ឌសង្គម និងបរិស្ថានអាចខុសគ្នាយ៉ាងខ្លាំងនោះទេ។ ក៏ប៉ុន្តែសកម្មភាពដ៏គ្រោះថ្នាក់ អាចរួមមានការចាប់យកដី និងការបង្ខំឱ្យសហគមន៍រុះរើទីលំនៅចេញដើម្បីយកដីសាងសង់ហេដ្ឋារចនាសម្ព័ន្ធ, ការរំលោភលើសេរីភាពប្រជាពលរដ្ឋ និងការប្រហារតបតនឹងការតវ៉ារបស់អ្នកស្រុក,ពលកម្មដោយបង្ខំ និងការបំផ្លាញបរិស្ថានដោយការសាងសង់ហេដ្ឋារចនាសម្ព័ន និងការធ្វើឱ្យកខ្វក់ដោយសារការកំពប់ប្រេងនៅក្នុងសមុទ្រ និងការធ្លាយប្រេងពីបំពង់ និងឧបករណ៍នានានៅលើដីគោក។

### *ការប្រើប្រាស់ចុងក្រោយនូវចំណូលពីប្រេង និង ឧស្ម័ន*

ប្រទេសនីមួយៗនឹងមានកាលទេសៈ សេចក្តីត្រូវការ និងអាទិភាពផ្ទាល់ខ្លួនដែលកំណត់ ថាតើទីបំផុត ចំណូលទាំងអស់របស់ខ្លួនត្រូវយកទៅប្រើប្រាស់សំរាប់អ្វីខ្លះ ចំណាយយ៉ាងដូចម្តេច និងនៅពេលណា ហើយចំណូលពីប្រេង និងឧស្ម័ន មិនសុទ្ធតែត្រូវចាត់ទុកជាចំណូលខុសប្លែកពីចំណូលដទៃទៀតនោះទេ។ មិនសុទ្ធតែមានហេតុផលណាមួយ ដើម្បីដកទុកដោយឡែកនូវចំណូលពីប្រេង និងឧស្ម័ន សំរាប់គោលដៅជាក់លាក់ណាមួយនោះទេ។ ប្រទេសនីមួយៗ ត្រូវឆ្លើយតបទៅនឹងសេចក្តីត្រូវការ និងអាទិភាពរបស់ខ្លួន ព្រមទាំងការចំណាយរបស់ខ្លួន ដែលជាផ្នែកមួយនៃដំណើរការរៀបចំគំរោងថវិកា និងការអភិវឌ្ឍន៍ត្រឹមត្រូវមួយ។

ទោះជាយ៉ាងនេះក្តី បញ្ហាដែលលេចឡើងជាទូទៅគឺ ថាតើថវិកាត្រូវគេយកទៅប្រើដើម្បីផលប្រយោជន៍ចាំបាច់សំរាប់សង្គម ឬសំរាប់ការវិនិយោគ (រូបី ឬអរូបី) សំរាប់ពេលអនាគត។ (ជួនកាលវិធានការនេះ ត្រូវគេហៅថា *សមធម៌អន្តរជំនាន់* ។

## ប្រេង និងឧស្ម័ននៅក្នុងប្រទេសកម្ពុជា

### *ការរុករកក្នុងទសវត្សឆ្នាំ ១៩៩០*[៥]

ការរុករកប្រេង និងឧស្ម័ននៅក្នុងប្រទេសកម្ពុជា បានចាប់ផ្តើមនៅដើមទសវត្សឆ្នាំ ១៩៩០។ អាជ្ញាប័ណ្ណសំរាប់រុករក ត្រូវបានគេផ្តល់ឱ្យ *សហគ្រាសរុករកប្រេង* (Enterprise Oil Exploration) និងដៃគូរបស់ខ្លួន, *ក្រុមហ៊ុនរុករកប្រេងកម្ពុជា* (CAMPEX) (តាមមើលប្រហែលជាក្រុមហ៊ុនរដ្ឋ ហើយឥឡូវនេះគ្មានក្រុមហ៊ុននេះឡើយ ), *ក្រុមហ៊ុនព្រីមៀរអយប៉ាស៊ីហ្វិក* (Premier Oil Pacific Ltd) និង *ក្រុមហ៊ុនរុករកប្រេងអ៊ីដេមីតស៊ុយកម្ពុជា* (Idemitsu Cambodia Oil Exploration) ចាប់តាំងពីឆ្នាំ ១៩៩១មក ដែលពេលនោះបទបញ្ញត្តិស្តីប្រេងកាត ឆ្នាំ ១៩៩១ បានចេញរួចហើយ។ ការសិក្សាស្រាវជ្រាវត្រូវបានធ្វើឡើង, អណ្តូងត្រូវបានខួង ហើយប្រេង និងឧស្ម័នមួយចំនួនត្រូវបានរកឃើញ។ ប៉ុន្តែនៅចុងឆ្នាំ ១៩៩៧ ក្រុមហ៊ុនទាំងអស់បានបោះបង់ចោលកិច្ចព្រមព្រៀងរបស់គេ ដែលតាមមើលប្រហែលជាដោយសារបណ្តាលមកពីការធ្លាក់ចុះនៃតំលៃប្រេងពិភពលោកដែរ។ ប៉ុន្តែក្រោយមកចំណាប់អារម្មណ៍ក្នុងការរុករកប្រេង និងឧស្ម័ន បានកើតមានឡើងវិញ។

### *ប្លុកសំរាប់រុករក*

តំបន់ដែលអាចផ្តល់អាជ្ញាប័ណ្ណសំរាប់ការជីកខួងអណ្តូង ត្រូវគេចែកចេញជាប្លុកពី A ដល់ F និងតំបន់ត្រួតស៊ីគ្នា (Overlapping Claim Area ) ដែលស្ថិតនៅក្នុងសមុទ្រ និងប្លុកនៅលើដីគោក

[៥] សន្ទរកថារបស់ឯកឧត្តម *សុខ អាន* ថ្ងៃទី ១៥ សីហា ២០០២, http://www.camnet.com.kh/ocm/government/government134.htm

មួយចំនួនទៀត [៦]។ ប្លុក A គឺជាទី តាំងដែលមានទំហំ ៦២៧៨ គីឡូម៉ែត្រក្រឡា នៅក្នុងឈូងសមុទ្រថៃជាពិសេសគឺ " *តំបន់បាតខ្ទះរបស់ខ្មែរ* " ដែលមានជំរៅទឹកជាមធ្យមមាន ៧០ ម៉ែត្រ ហើយការរុករកមានដំណើរទៅមុខយ៉ាងខ្លាំងនៅក្នុងប្លុកនេះ។ ប្លុក B ទៅ F ស្ថិតនៅក្បែរតំបន់ឆ្នេរសមុទ្រកម្ពុជា។ ចំណែកឯតំបន់ដែលហៅ " *ទាមទារត្រួតគ្នា* " គឺជាតំបន់ដែលខិតទៅជិតប្រទេសថៃ ហើយដែលទំនងជាឬអាចមានការផ្តល់អាជ្ញាប័ណ្ណជាន់គ្នា ដោយរដ្ឋាភិបាលប្រទេសថៃ និងកម្ពុជា។

### ***អាជ្ញាប័ណ្ណដែលបានផ្តល់មកទល់បច្ចុប្បន្ន***

ពត៌មានអំពីអាជ្ញាប័ណ្ណដែលបានផ្តល់ ព្រមទាំងលក្ខខណ្ឌរបស់វា នៅមានការកំរិតនៅឡើយ ហើយជួនកាលពត៌មានដែលទទួលបានមានលក្ខណៈផ្ទុយគ្នា។ មានសេចក្តីរាយការណ៍តាមសារពត៌មានជាច្រើន អំពីចំណាប់អារម្មណ៍ និងការចរចាជាទូទៅអំពីអាជ្ញាប័ណ្ណនេះ។

### **ប្លុក A – ឆេវរ៉ុន/មីតស៊ី/ ជីអេស កាល់តិច (Chevron/Mitsui/GS Caltex)**

ក្នុងឆ្នាំ ២០០២ ឯកឧត្តម សុខ អាន ប្រធានអាជ្ញាធរជាតិប្រេងកាតកម្ពុជា បានប្រកាសពីការចុះហត្ថលេខាជាផ្លូវការលើកិច្ចព្រមព្រៀងលើការបែងចែកផលិតផលជាមួយសហាគម ដែលរួមមាន ឆេវរ៉ុន (៧០%) និង មីអេកូជប៉ុន (Japanese Moeco) ដែលកាន់កាប់ដោយ Mitsui (៣០%) ទាក់ទងទៅនឹងប្លុក A។ កម្មវិធីការងាររបស់ពួកគេ គឺត្រូវត្រួតពិនិត្យឡើងវិញនូវទិន្នន័យស្តីពីការរុករកកន្លងមក និងខួងអណ្តូងរុករកចំនួន៦។ នៅក្នុងឆ្នាំ ២០០៥ ឆេវរ៉ុន បានប្រកាសថា បានរកឃើញប្រេងនៅក្នុងអណ្តូងចំនួន៤។ ការចុះហត្ថលេខាបន្តទៅទៀតលើកិច្ចព្រមព្រៀងអំពីការបែងចែកផលិតផល នៅថ្ងៃទី ៦ កក្កដា ឆ្នាំ ២០០៦ មានផ្សាយនៅក្នុងកាសែតមានភ្នំពេញប៉ុស្ត៍ ក៏ដូចជាការដែល ឆេវរ៉ុន បានដឹកចូលនូវឧបករណ៍សំរាប់ជីកអណ្តូង ដែលរួមមានម៉ាស៊ីនស្ទូច និងបង្គោលដែកចំនួនពីរពាន់តោនចូលមកកំពង់ផែក្រុងព្រះសីហនុ ហើយបានជួលដីមួយហិចតារបស់កំពង់ផែសំរាប់រយៈពេលមួយឆ្នាំ [៧]។ ប៉ុន្តែកិច្ចព្រមព្រៀងលើការចែកផលិតផលទាំងនេះ មិនត្រូវបានប្រកាសជាសាធារណៈឡើយ។ក្រុមហ៊ុន ឆេវរ៉ុន បានផ្ទេរភាគហ៊ុនរបស់ខ្លួនចំនួន ១៥% ទៅឱ្យ SG Caltex (ពីមុនឈ្មោះថា LG Caltex) ដែលកាន់កាប់ ៥០/៥០ ដោយ ឆេវរ៉ុន និង GS Group របស់កូរ៉េខាងត្បូង។

---

[៦] ប្លុកទាំងឡាយត្រូវបានបង្ហាញនៅក្នុងផែនទីមួយនៃបទបង្ហាញមួយដោយលោក *តែ ដួង ដារា* មកពីអាជ្ញាធរជាតិប្រេងកាតកម្ពុជា" ការអភិវឌ្ឍន៍វិស័យប្រេងកាត ទស្សនវិស័យនៃប្រទេសកម្ពុជា: *តំបន់ក្នុងសមុទ្រកម្ពុជា និងតំបន់អាងទន្លេសាបនៃដីគោកកម្ពុជា* " នៅក្នុងសន្និសិទបច្ចេកវិទ្យា លើកទី៤ ស្តីពីប្រេងកាតអាស៊ី ថ្ងៃទី ១៨ មករា ២០០៦ ដែលជាឧបសម្ព័ន្ធរបស់សេចក្តីព្រាងនៃការសិក្សាពីទំហំនៃឧស្សាហកម្មនិស្សារណកម្មទ្រង់ទ្រាយធំនៅក្នុងប្រទេសកម្ពុជា ដោយអង្គការ អុកស្វាមអាមេរិក ហើយដែលត្រូវបានប្រើប្រាស់នៅក្នុងបទបង្ហាញ ដល់អង្គការសង្គមស៊ីវិល នៅខែសីហា ២០០៦។ ពត៌មាននៅក្នុងការសិក្សាពីទំហំនៃការផ្តល់អាជ្ញាប័ណ្ណ កំពុងស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ។

[៧] ថ្ងៃទី ១៤-២៧ កក្កដា ២០០៦ www.phnompenhpost.com

### ប្លុក B - ក្រុមហ៊ុនប្រេងកាតសិង្ហបូរី/ភីធីធី/រីហ្សសហ្វុល និង/ឬ ស៊ីអ៊ិនអូអូស៊ី ឬ តូតាល់

នៅថ្ងៃទី ២៤ សីហា ២០០៥ ក្រុមហ៊ុនប្រេងកាតសឹង្ហបូរី បានប្រកាស និងផ្សាយតាមគេហទំព័ររបស់ខ្លួនថា ក្រុមហ៊ុនបានចុះកិច្ចព្រមព្រៀងសំរាប់ចំណែក ៣០% នៅក្នុងប្លុក B ជាមួយនឹង អ្នករកស៊ីរួមគ្នាដទៃទៀត ដែលក្នុងនោះរួមមាន PTTEP International Limited របស់ប្រទេសថៃ ដែលជាអ្នកប្រតិបត្តិមួយដែលមានចំណែក ៣០% និង Cooper Energy Limited ដែលមានចំណែក ១០%។ ក្រុមហ៊ុនមានកម្មវិធីសំរាប់ការងាររុករករយៈពេល៣ឆ្នាំ ដែលរួមមានការជីកអណ្តូងរុករកមួយ និងការប្រមូលទិន្នន័យស៊ីស្មិក ៣វិមាត្រ (3D seismic data[៨]) លើផ្ទៃដី ២០០គីឡូម៉ែត្រក្រឡា[៩]។ នៅថ្ងៃ ទី ៥ មករា ២០០៧ ក្រុមហ៊ុនប្រេងកាតសឹង្ហបូរីបានប្រកាសថា ខ្លួន និង PTT ព្រមទាំងក្រុមហ៊ុន Resourceful បានទិញភាគហ៊ុន ១០% របស់ CEL ដោយយោងតាមការឯកភាពពីអាជ្ញាធរជាតិប្រេងកាតកម្ពុជា[១០]។

ការណ៍នេះអាចទំនងជាការសន្និដ្ឋានត្រឹមត្រូវ ប៉ុន្តែថ្មីៗនេះក៏មានសេចក្តីរាយការណ៍សារពត៌មានថា សាជីវកម្មប្រេងជាតិក្នុងសមុទ្ររបស់ចិន (CNOOC) និងតូតាល់ កំពុងតែប្រកួតប្រជែង ដើម្បីទទួលបានកិច្ចសន្យា " *ទាំមុខ* " នៅក្នុងប្លុក B [១១]។ ដូច្នេះ អាចមានកិច្ចព្រមព្រៀងជីកអណ្តូងច្រើនជាងមួយដែលរដ្ឋាភិបាលបានផ្តល់ឱ្យ នៅក្នុងប្លុក B (ប្រហែលជាស្ថិតនៅក្នុងទីតាំងផ្សេងគ្នា) ឬក៏សេចក្តីការណ៍របស់សារពត៌មាន មិនត្រឹមត្រូវ។

### ប្លុក E - មិដកូ/ជេអេចអិល (Medco/JHL)

ក្នុងខែតុលា ២០០៦ ក្រុមហ៊ុនសាធារណៈរបស់ឥណ្ឌូនេស៊ី ឈ្មោះថា Pt Medco Energi Internatsional បានប្រកាស ហើយផ្សាយលើគេហទំព័ររបស់ខ្លួន[១២] ថាខ្លួន រួមជាមួយដៃគូឈ្មោះ JHL Petroleum បានចុះកិច្ចព្រមព្រៀងជាមួយអាជ្ញាធរជាតិប្រេងកាតកម្ពុជា សំរាប់ការរុករកនៅក្នុងប្លុក E។ មីដកូ មានចំណែក ៩០% ហើយគឺជាអ្នកប្រតិបត្តិ ។ រីឯ JHL Petroleum មានចំណែក ១០%។

---

[៨] 3D seismic data ( three- dimensional seismic data) គឺជាទិន្នន័យដែលបានមកពីការស្ទង់ស៊ីសស្មិកដែលមានវិមាត្របីទិស។

[៩] www.spc.com.sg/investor_centre/press_releases/SPC+secures+new+exploration+block%2C+offshore+Cambodia/127

[១០] www.spc.com.sg/investor_centre/press_releases/SPC+secures+new+exploration+block%2C+offshore+Cambodia/127

[១១] " *កម្ពុជាកំពុងក្លាយជាកន្លែងដែលសំបូរកំណប់ថាមពល* " Asia Times Online, ថ្ងៃទី ២៦ មករា ២០០៧ ។ " *ប្រទេសកម្ពុជាបាននិយាយថា ក្រុមហ៊ុននានាផ្តុំគ្នាចូលមកប្រទេសនេះ ដើម្បីស្រាវជ្រាវរកប្រេង* ", Associated Press, ថ្ងៃទី ១៦ មករា ២០០៧។" " *កម្ពុជាត្រូវបានចាត់ទុកថាជាប្រទេសមានលាភធំពីការអភិវឌ្ឍន៍ប្រេង និងឧស្ម័ន* ", World Politics Watch, ថ្ងៃទី ៤ ធ្នូ ២០០៦។ " *កម្ពុជាត្រៀមខ្លួនធ្វើជាប្រទេសរីកចំរើនខាងវិស័យប្រេង ហើយប្រទេសចិនអាចទទួលបានផលប្រយោជន៍ពីវា* " Dow Jones Newswires, ថ្ងៃទី ២៧ តុលា ២០០៦។ " *ក្រុមហ៊ុនប្រេងចិន និងបារាំងដណ្តើមគ្នាលើកំណប់ប្រេងប្រទេសកម្ពុជា* ", University of Alberta China Institute, ថ្ងៃទី ២៨ សីហា ២០០៦។

[12] /www.medcoenergi.com/press_release/04oct06_acquired_block_e_offshore_cambodia.pdf

### ក្រុមហ៊ុនផ្សេងទៀត

មានសេចក្តីយោងមួយចំនួននៅលើសារពតមាន អំពីចំណាប់អារម្មណ៍ និងការដេញថ្លៃ ពីក្រុមហ៊ុនប្រេងក្នុងសមុទ្រជាតិរបស់ចិន ( China National Offshore Oil Company ), សាជីវកម្មប្រេងកាតជាតិរបស់ចិន (China National Petroleum Corporation), ក្រុមហ៊ុន Zhuhai Zhenrong Co និង X-Change Corp (US) ព្រមទាំងក្រុមហ៊ុនរបស់ជប៉ុន កូរ៉េខាងត្បូង គុយវ៉ែត ថៃ ម៉ាឡេស៊ី សិង្ហបូរី អូស្ត្រាលី ឥណ្ឌូនេស៊ី និង រុស្ស៊ី [១៣] ។

### *ផលប៉ះពាល់លើបរិស្ថាន និងសង្គម*

ចំណុចនៃការពិភាក្សាកន្លងមក គឺផ្តោតលើតម្លាភាព និងការគ្រប់គ្រងប្រាក់ចំណូល ដោយសារទំនងជាឈរលើមូលដ្ឋានថា ការជីកប្រេង និងឧស្ម័ននឹងធ្វើឡើងនៅក្នុងសមុទ្រ និងមិនទាន់មានផែនជាក់លាក់ណា សំរាប់ការអភិវឌ្ឍន៍ខាងសកម្មភាពចុងខ្សែ នៅឡើយ ។

ទោះជាយ៉ាងនេះក្តី យ៉ាងហោចណាស់ក៏មានបញ្ហាដែលមានជាប់ជាមួយនឹងការជីករុករក និងការសាងសាង់ ការប្រតិបត្តិ និងរុះរើជើងខ្ទង់ដែរ ហើយតាមពិត មានប្លុកនៅលើផ្ទៃដីមួយចំនួន ដែលរដ្ឋាភិបាលអាចនឹងយល់ព្រមចេញអាជ្ញាប័ណ្ណ។ អាចមានការស្ថាបនាបំពង់បង្ហូរដើម្បីនាំប្រេងទៅកាន់ដីគោក, ការពង្រីកកំពង់ផែក្រុងព្រះសីហនុ និងបញ្ហាទាក់ទងនឹងការដឹកជញ្ជូនប្រេងតាមសមុទ្រ ឬបញ្ហាបំពង់បង្ហូរសំរាប់នាំប្រេងទៅក្រៅប្រទេស។

បើសិនជាគេចង់ប្រើប្រាស់ឧស្ម័នធម្មជាតិ ជាជាងចាត់ទុកជាផលិតផលកាកសំណល់ នោះគេត្រូវបង្ហូរឧស្ម័នតាមបំពង់ទៅឱ្យអ្នកប្រើនៅក្នុងប្រទេសកម្ពុជា ឬប្រទេសជិតខាង។

រដ្ឋាភិបាលទំនងជាពិចារណាថាតើខ្លួនគួរវិនិយោគ ឬផ្តល់ឧបត្ថម្ភធនដល់ការសាងសង់រោងចក្រចំរាញ់ប្រេង និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជាឬយ៉ាងណា [១៤] ។ វាអាចជាការ

---

[១៣] សូមមើលសេចក្តីរាយការណ៍សារព័ត៌មាន នៅក្នុងសេចក្តីយោងលេខ ១១ ខាងលើ " *កម្ពុជាសង្ឃឹមថានឹងចាប់ផ្តើមការផលិតប្រេងនៅក្នុងឆ្នាំ ២០០៩* ", ទីភ្នាក់ងារព័ត៌មាន Reuters, ថ្ងៃទី ១៩ មករា ២០០៧ ។ " *ប្រទេសកម្ពុជាសុំរុស្ស៊ីឱ្យលើកលែងបំណុលចំនួន១,៥ កោដិដុល្លារ* ", កាសែត The Cambodia Daily, ថ្ងៃទី ៣០ មករា ២០០៧។

[១៤] នៅឆ្នាំ ២០០៣ លោក *តែ ដួងតារា* អគ្គនាយកអាជ្ញាធរជាតិប្រេងកាត ដែលត្រូវបានដកស្រង់សំដីដោយកាសែតភ្នំពេញប៉ុស្តិ៍ បាននិយាយយោងទៅលើគំរោងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដូចជា ផ្លូវថ្នល់ រោងចក្រ និងឧស្សាហកម្មថាមពល បំពង់ឧស្ម័នពីមាត់អណ្តូងទៅឆ្នេរសមុទ្រនៅក្រុងព្រះស៊ីហនុ, រោងចក្រអគ្គិសនីដើរដោយឧស្ម័នចំនួន៣ ខ្សែបញ្ជូនចរន្តទៅភ្នំពេញ និងថាមពលក្នុងតំលៃថោក។ មានរបាយការណ៍នៅក្នុងការបោះពុម្ពមួយនៅប្រទេសបង់ក្លាដេស ឈ្មោះថា The Financial Express ពីថ្ងៃទី ១២ ឧសភា ២០០៦ អំពីសេចក្តីប្រកាសមួយរបស់ Mitsui អំពីភាពជាដៃគូជាមួយអាជ្ញាធរជាតិប្រេងកាតកម្ពុជា ដើម្បីចាប់ផ្តើមការកសាងរោងចក្រចំរាញ់ www.financialexpress-bd.com និងក្នុង World Politics Watch: www.worldpoliticswatch.com/article.aspx?id=382 " *កម្ពុជាត្រូវបានចាត់ទុកថា ជាប្រទេសមានលាភធំពីការអភិវឌ្ឍន៍ប្រេង និងឧស្ម័ន* " World Politics Watch ថ្ងៃទី ៤ ធ្នូ ២០០៦ និងនៅក្នុង Dow Jones Newswires ថ្ងៃទី ២៧ ខែតុលា ២០០៦ " *កម្ពុជាត្រៀមខ្លួនធ្វើជាប្រទេសរីកចំរើនខាងវិស័យប្រេង ហើយប្រទេសចិនអាចទទួលបានផលប្រយោជន៍ពីវា* " www.rigzone.com/news/article.asp?a_id=37532 ដែលនិយាយថា China National Engineering Group Corporation នឹងជួយបង្កើតរោងចក្រចំរាញ់ប្រេងមួយនៅក្នុងក្រុងព្រះស៊ីហនុ ក្នុងតំលៃប៉ាន់ស្មានប្រហែលជា ២៤០ លានដុល្លារ។

ផ្គត់ផ្គង់តំរូវការក្នុងស្រុក ផ្តល់សុវត្ថិភាពក្នុងការផ្គត់ផ្គង់ឥន្ធនៈដើម្បីធ្វើឱ្យកម្ពុជាមិនសូវមានបញ្ហាថាមពល ដោយសារការកាត់ផ្តាច់ពីប្រទេសផ្សេងៗ ព្រមទាំងផ្តល់ផលិតផលចំរាញ់រួចសំរាប់នាំចេញ។ ក៏ប៉ុន្តែ ទំនងជាមានការខ្វែងគំនិតគ្នាយ៉ាងខ្លាំងខាងសេដ្ឋកិច្ច ចំពោះការវិនិយោគ ឬការឧបត្ថម្ភធននេះ[១៥] ។ ក្រុមការងារប្រទេសម្ចាស់ជំនួយមួយ ដែលដឹកនាំដោយធនាគារអភិវឌ្ឍន៍អាស៊ី ទំនងជាកំពុងពិនិត្យមើល ជាពិសេស ទៅលើបញ្ហា "*ហេដ្ឋារចនាសម្ព័ន្ធ*" ដូចជាថាតើវាគួរមានរោងចក្រចំរាញ់ប្រេង ឬជាក្រុមហ៊ុនប្រេងជាតិឬអត់។ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ក៏បាន " ផ្តួចផ្តើមឱ្យមានការបណ្តុះបណ្តាលសំខាន់ៗ មួយចំនួន ស្តីពីការវិភាគលើចំណាយ-ចំណេញរបស់គំរោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈធំៗ ក្នុងគោលដៅជួយធ្វើឱ្យប្រសើរឡើងដល់ការប្រើប្រាស់ប្រកបដោយវិចារណញាណ នូវចំណូលដែលបានមកពីប្រេងនៅថ្ងៃមុខ និងធ្វើឱ្យការចំណាយសាធារណៈរិតតែមានលក្ខណៈទូទៅ "[១៦]។

### ***ចំណូលដែលនឹងអាចទទួលបាន***

មានសេចក្តីរាយការណ៍មកថា ការបូមប្រេងឆៅ និងឧស្ម័ន ជាពិសេសនៅក្នុងប្លុក A នឹងចាប់ផ្តើមនៅឆ្នាំ ២០០៩។ សេចក្តីរាយការណ៍នេះអាចមិនទាន់ប្រាកដទេ ដោយហេតុថាក្រុមហ៊ុន ឆេវរ៉ុន កំពុងស្ថិតក្នុងដំណាក់កាលរុករក និងវាយតំលៃនៅឡើយ និងម្យ៉ាងវិញទៀត បរិមាណប្រេងនិងឧស្ម័ននៅពេលដំបូងទំនងជានឹងតិចជាងបរិមាណប្រេង និងឧស្ម័នជាមធ្យមប្រចាំឆ្នាំ ក្នុងរយៈពេលវែង ។ មិនមានពត៌មានណាមួយសំរាប់យកមកធ្វើជាមូលដ្ឋាន ដើម្បីការប៉ាន់ស្មានចំណូលពីតំបន់ផ្សេងៗទៀតទេ ។ លើសពីនេះ សេចក្តីសំរេចចិត្តជាច្រើនដែលប៉ះពាល់ដល់ចរន្តចំណូល និងកិច្ចព្រមព្រៀងទាំងឡាយ ទំនងជានឹងត្រូវគេធ្វើឡើង រវាងពីពេលនេះ និងឆ្នាំ ២០០៩។ ដោយមូលហេតុនេះហើយ ចាំបាច់ត្រូវធ្វើការពិចារណាលើបញ្ហានេះជាបន្ទាន់។

មានការកត្តាជាច្រើន ដែលប៉ះពាល់ដល់ចំនួន និងពេលវេលាទទួលបានប្រាក់ចំណូលពីផលិតកម្មប្រេង និងឧស្ម័នដែលបានគូសបញ្ជាក់ពីខាងដើម ប៉ុន្តែគេទំនងជាទទួលស្គាល់ថា ប្រាក់ចំណូលនេះ នឹងមានក្រាស់ក្រែល ហើយរួមចំណែកខ្លាំងក្លាដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច ។ កាលពីខែ មិថុនា ឆ្នាំ ២០០៦ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ បានផ្តល់នូវការប៉ាន់ប្រមាណថា នឹងមានចំណូល ១.៧ កោដិ ដុល្លារ ក្នុងមួយឆ្នាំ សំរាប់រយៈពេល ១០ ឆ្នាំ ដោយផ្អែកលើការប៉ាន់ស្មានជាដំបូងៗដោយក្រុមហ៊ុន ឆេវរ៉ុន ចំពោះកំណប់ប្រេងនៅក្នុងប្លុក A។ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិបានថ្លែងថា ប្រាក់ចំណូលដែលប៉ាន់ស្មាននោះ

---

[១៥] ទំព័រ៩-១៦ នៃ Harvard Kennedy School Review ស្តីពីលទ្ធភាពអភិវឌ្ឍន៍ និងជំរើសសំរាប់វិស័យប្រេង និងឧស្ម័នកម្ពុជា, របាយការណ៍បេសកកម្មចុងក្រោយ ថ្ងៃទី ១១-២៣ ខែកក្កដា ឆ្នាំ ២០០៥ ។ ទំព័រ ៩-១១ នៃ " *ការវិភាគ SWOT សំរាប់សេដ្ឋកិច្ចកម្ពុជា* ", ខែធ្នូ ២០០៥ ។

[១៦] ទំព័រ ១ នៃទស្សនៈការងាររបស់កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ចំពោះការជំពាក់វ៉ាក់វិនខាងសេដ្ឋកិច្ច-សង្គម សំរាប់ប្រទេសកម្ពុជា នូវប្រេង និងឧស្ម័ន, ខែមិថុនា ឆ្នាំ ២០០៦។

នឹងមានចំនួនបីដងនៃជំនួយអភិវឌ្ឍន៍បរទេស នាពេលបច្ចុប្បន្ន ដែលស្មើ ៣០% នៃផលិតផលសរុបក្នុងស្រុករបស់កម្ពុជា កាលពីឆ្នាំទៅ ហើយធ្វើឱ្យប្រាក់ចំណូលប្រចាំឆ្នាំម្នាក់ៗ កើន ១៣០ ដុល្លារ ថែមទៀត [១៧] ។

### *ក្របខណ្ឌច្បាប់*

មានបញ្ហាផ្នែកច្បាប់មួយចំនួន ដែលត្រូវដោះស្រាយ ទាក់ទងនឹងវិស័យប្រេង និង ឧស្ម័ននៅក្នុងប្រទេសកម្ពុជា។

### ច្បាប់ថ្មីស្តីពីប្រេងកាត

បទបញ្ញត្តិស្តីពីប្រេងកាត ឆ្នាំ ១៩៩១ បានចេញនៅពេលដែលការរុករកប្រេង និងឧស្ម័ននៅក្នុងប្រទេសកម្ពុជា បានចាប់ផ្តើមនៅដើមទសវត្សឆ្នាំ ១៩៩០ [១៨] ។ បទបញ្ញត្តិនោះរួមមាន ដំណើរការដេញថ្លៃកិច្ចសន្យាបែងចែកផលិតផល ដោយមានគំរូកិច្ចសន្យាភ្ជាប់ជាមួយផង (ទោះបីជាគ្មានឯកសារបកប្រែជាភាសាអង់គ្លេស ស្តីពីបទបញ្ញត្តិស្តីពីប្រេងកាត ឆ្នាំ ១៩៩១ មានដាក់នៅក្នុងប្រព័ន្ធអ៊ិនធឺណែតក៏ដោយ) ការកំណត់ព្រំដែននៃប្លុកសំរាប់រុករក, រយៈពេលនៃការរុករក, កម្មវិធីការងារ, ថវិកា និងការបែងចែកប្រេងកាត, ពន្ធ, សេចក្តីណែនាំអំពីដំណើការអាជីវកម្មប្រេង, របាយការណ៍របស់អ្នកម៉ៅការជូនរដ្ឋាភិបាល ប្រាក់បង់ និងប្រាក់រង្វាន់ដែលអ្នកម៉ៅការត្រូវបង់ឱ្យរដ្ឋាភិបាល, អធិការកិច្ចដោយរដ្ឋាភិបាលនៅទីកន្លែងជាប់សន្យា, ការបង្កើតក្រុមប្រឹក្សាពិគ្រោះយោបល់ស្តីពីប្រេងកាត, សិទ្ធិរបស់រដ្ឋាភិបាលក្នុងការចូលរួមក្នុងប្រតិបត្តិការវិស័យប្រេងកាត និងបញ្ហាដទៃទៀត។

ទោះជាយ៉ាងនេះក្តី ទំនងជាមានច្បាប់ថ្មីស្តីពីប្រេងកាត ។ គេបានតែងតាំងទីប្រឹក្សាច្បាប់ ដោយប្រើថវិកាម្ចាស់ជំនួយ ដើម្បីជួយរដ្ឋាភិបាលទាក់ទងនឹងវិស័យប្រេងកាត។ Wikborg Rein ដែលជាក្រុមហ៊ុនច្បាប់ប្រទេសណរវ៉េស បានថ្លែងនៅសេចក្តីប្រកាសសារព័ត៌មាននៅក្នុង ខែតុលា ឆ្នាំ ២០០៦ ថា ខ្លួនត្រូវបានរដ្ឋាភិបាលកម្ពុជាតែងតាំង ដោយប្រើមូលនិធិ Norad ហើយនឹងធ្វើការនៅលើកិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសថៃ, ច្បាប់ស្តីពីប្រេងកាត, បទបញ្ញត្តិស្តីពីកិច្ចព្រមព្រៀងក្នុងការចែកផលិតផល និងអាជ្ញាប័ណ្ណសំរាប់ការរុករកក្នុងសមុទ្រ [១៩] ។ អ្នកច្បាប់អូស្ត្រាលី ក៏បានជួយក្នុងវិស័យនេះដែរ។

---

[១៧] កម្មវិធី Insights for Action របស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ " *កំណត់ផ្តល់យោបល់សង្ខេប ស្តីពីការជំពាក់វាក់វិន* ខាងសេដ្ឋកិច្ច-សង្គម និងហិរញ្ញវត្ថុ នៃប្រេង និងឧស្ម័នក្នុងសមុទ្ររបស់កម្ពុជា។

[១៨] ការស្រាវជ្រាវថ្មីៗលើប្រសាសន៍របស់ឯកឧត្តម *សុខ អាន* ថ្ងៃទី ១៥ សីហា ២០០២ http://www.camnet.com.kh/ocm/government/government134.htm

[១៩] www.wrco.no/index.php?struct=45&join=760&lang=eng

នៅក្នុងសេចក្តីប្រកាសពត៌មានរបស់ Wikborg Rein មិនមាននិយាយយោងអំពីការបើកចំហ ឬការត្រួតពិនិត្យចំណូល និងយន្តការគ្រប់គ្រងដទៃទៀតឡើយ ដូចជាមូលនិធិប្រេងកាតជាដើម។ ទោះយ៉ាងណាក្តី ការណ៍នេះអាចស្ថិតនៅក្នុងវង្វង់នៃច្បាប់ស្តីប្រេងកាតមួយ ក៏ប៉ុន្តែគេមិនដឹងថាតើរដ្ឋាភិបាលបានប្រាប់ឱ្យអ្នកច្បាប់គិតគូរដល់បញ្ហានេះ ឬអត់។

**អាជ្ញាធរជាតិប្រេងកាតកម្ពុជា** (CNPA)

បទបញ្ញត្តិស្តីពីប្រេងកាត ១៩៩១ កាលពីដំបូងបានផ្តល់សិទ្ធិដល់ក្រសួងឧស្សាហកម្ម (ឥឡូវនេះជាក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME)) ជាតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជាទាក់ទិននឹងវិស័យប្រេង និងឧស្ម័ន។

ក៏ប៉ុន្តែ អាជ្ញាធរជាតិប្រេងកាតនៃកម្ពុជា (CNPA) ទំនងជាត្រូវបង្កើតឡើងនៅឆ្នាំ ១៩៩៨ ដើម្បីគ្រប់គ្រងការអភិវឌ្ឍន៍ឧស្សាហកម្មប្រេងកាត, ផ្តល់នូវក្របខណ្ឌច្បាប់, គាំទ្រដល់ការរុករក និងស្វែងរកវិនិយោគបរទេស[២០]។ អាជ្ញាធរនេះមានឯកឧត្តម *សុខ អាន* ជាប្រធាន។ យោងតាមលោក *តែ ដួងតារា*[២១] អគ្គនាយកអាជ្ញាធរជាតិប្រេងកាតកម្ពុជា ការគ្រប់គ្រងលើវិស័យប្រេងត្រូវបានដកពីក្រសួងឧស្សាហកម្មមកដាក់នៅក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីកាត់បន្ថយជំហាននានាដែលទាមទាររវាងក្រសួងឧស្សាហកម្ម និងនាយករដ្ឋមន្ត្រី ក្នុងគោលបំណងសន្សំពេលវេលា និងថវិការបស់ក្រុមហ៊ុន និងដើម្បីលើកទឹកចិត្តដល់ការវិនិយោគ។

ធនាគារពិភពលោក ដែលជាផ្នែកមួយនៃគំរោងជំនួយបច្ចេកទេសរបស់ខ្លួនដល់រដ្ឋាភិបាលកម្ពុជាស្តីពីចំណូលបានពីប្រេង ក៏បានពិនិត្យមើលជាពិសេសផងដែរអំពីលំហូរនៃប្រាក់ចំណូលពីប្រេង នៅក្នុងបរិបទច្បាប់បច្ចុប្បន្ន ហើយបានកត់សំគាល់ឃើញថា ប្រកាសថ្មីមួយអាចត្រូវធ្វើឡើងរួមគ្នា រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីធានាថា ចំណូលពីប្រេងចេញពីអាជ្ញាធរជាតិប្រេងកាតកម្ពុជា បានទៅដល់រតនាគារជាតិ ។ ចំណុចនេះកំពុងត្រូវបានពិភាក្សានៅក្នុងកិច្ចសន្ទនាស្តីពីជំរើសដើម្បីគាំទ្រដល់ការកាត់បន្ថយភាពក្រីក្រ (PRSO) (សូមមើលការគ្រប់គ្រងចំណូល និងថវិកាខាងក្រោមនេះ)។

---

[២០] អ្នកនិពន្ធមិនអាចរកអនុក្រិត្យដើម្បីពិនិត្យមើលបានឡើយ ដូច្នេះផ្នែកនេះគឺផ្អែកលើអំណះអំណាងពីអ្នកដទៃទៀត។

[២១] កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី ១៥-២៨ សីហា ២០០៣: www.phnompenhpost.com

ក្រុមមួយមកពី Harvard Kennedy School បានពិនិត្យលើអាជ្ញាធរជាតិប្រេងកាតកម្ពុជា ហើយបានលើកជាអនុសាសន៍អំពីការបង្កើតអាជ្ញាធរនេះ [២២]។ ទាក់ទងនឹងមុខងាររបស់អាជ្ញាធរ ក្រុមនោះបានផ្តល់អនុសាសន៍ថា ដោយសារទំហំ និងជំនាញនៅមានកំរិត អាជ្ញាធរជាតិប្រេងកាតកម្ពុជាគួរផ្តោតលើការគ្រប់គ្រងបទបញ្ញត្តិអំពីការផលិតប្រេងនិងឧស្ម័នប៉ុណ្ណោះ ហើយមិនគួរព្យាយាមដើរតួនាទីប្រតិបត្តិការឡើយ ជាពិសេសលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដូចជាបំពង់បង្ហូរ រោងចក្រថាមពល ឬរោងចក្រចំរាញ់ជាដើម។ ក្រុមនោះបានសង្កត់ធ្ងន់ ពីតំរូវការសំរាប់ការអភិវឌ្ឍន៍បុគ្គលិករបស់អាជ្ញាធរជាតិប្រេងកាតកម្ពុជា ជាពិសេសលើតំរូវការឱ្យមានភូគព្ភវិទូ, វិស្វករប្រេងកាត, អ្នកគ្រប់គ្រង និងអ្នកច្បាប់ ប្រកបដោយសមត្ថភាព វិជ្ជាជីវៈ។ ក្រុមនេះក៏បានបញ្ជាក់ផងដែរអំពីតួនាទីជាអ្នកផ្តល់សេវា របស់អាជ្ញាធរជាតិប្រេងកាតកម្ពុជា។

**កិច្ចព្រមព្រៀងលើការបែងចែកផលិតផល** (PSAs)

មិនមានកិច្ចព្រមព្រៀងលើការចែកផលិតផលណាមួយរបស់ឆេវរ៉ុន ដែលទំនងជាត្រូវបានចុះហត្ថលេខានៅក្នុងឆ្នាំ ២០០២ និង ២០០៦ (សូមមើលខាងលើ) ត្រូវបានដាក់ផ្សាយជាសាធារណៈឡើយ។ ទោះជាយ៉ាងនេះក្តី មានការចង្អុលបង្ហាញជាទូទៅខ្លះ អំពីលក្ខខណ្ឌមួយចំនួននៃកិច្ចព្រមព្រៀងបែងចែកផលិតផល។

របាយការណ៍មួយពីឆ្នាំ ២០០៣[២៣] បានបង្ហាញថា មានចរន្តចំណូលបីប្រភេទៈ

- ថ្លៃសួយសារ ១២,៥ %
- ការចែកប្រាក់ចំណេញ "មានការខុសគ្នាបន្តិចបន្តួច ប៉ុន្តែស្ថិតនៅចន្លោះពី ៤០% ទៅ ៦៧%"
- ពន្ធលើប្រាក់ចំណូល ពី២៥ ទៅ ៥០ %

ក្រុមហ៊ុនប្រេងអាចដកថ្លៃដើមរបស់ខ្លួនចេញ "បន្ទាប់ពីការទូទាត់ថ្លៃសួយសារ ប៉ុន្តែត្រូវធ្វើឡើងមុនការចែកប្រាក់ចំណេញ និងមុនពន្ធលើប្រាក់ចំណូល "។

មាត្រា ២១ របស់បទច្បាប់ស្តីពីប្រេងកាត ឆ្នាំ១៩៩១ បានចែងថា អ្នកជាប់កិច្ចសន្យា ត្រូវបង់ឱ្យរាជរដ្ឋាភិបាលនូវៈ

- ថ្លៃសួយសារ យ៉ាងតិច ១២,៥ % លើតំលៃ (មាត្រា ៥៥) ប្រេងកាតដែលបានលក់ ឬបញ្ជូនចេញ
- ថ្លៃជួលដីប្រចាំឆ្នាំ (ថ្លៃឈ្នួលមានចែងក្នុងមាត្រា ៣៦-៣៩)
- ពន្ធលើប្រាក់ចំណូល ពី ២៥-៥០% នៃប្រាក់ចំណូលសុទ្ធ បានមកពីប្រតិបត្តិការប្រេង។ អត្រាពន្ធ និងវិធីទូទាត់មានកំណត់នៅក្នុងកិច្ចព្រមព្រៀងលើការបែងចែកផលិតផល ។

---

[២២] ទំព័រ២១-២៣ នៃ ការពិនិត្យអំពីទស្សនវិស័យនៃការអភិវឌ្ឍន៍ និងជំរើស សំរាប់វិស័យប្រេង និងឧស្ម័នកម្ពុជា, របាយការណ៍បេសកកម្មចុងក្រោយ, ខែកក្កដា ១១-២៣ ឆ្នាំ ២០០៥ ។

[២៣] ភ្នំពេញប៉ុស្តិ៍ ១៥-១៨ សីហា ២០០៣, www.phnompenhpost.com

- ថ្លៃចុះបញ្ជី និងថ្លៃឈ្នួល ឬសេវាដទៃទៀតដែលបានផ្តល់ដោយរដ្ឋាភិបាលកម្ពុជា តាមអត្រាមួយដែលអាចទទួលបានជាទូទៅ សំរាប់សេវាទាំងនោះ។
- ពន្ធ និងថ្លៃដទៃទៀត អាចមានកំណត់នៅក្នុងកិច្ចព្រមព្រៀងលើការបែងចែកផលិតផល។

មាត្រា ២២ ចែងថា សមតុល្យនៃប្រេងដែលផលិតបាន បន្ទាប់ពីដកថ្លៃសួយសារ និងចំណាយរបស់អ្នកជាប់កិច្ចសន្យាក្នុងការរុករក អភិវឌ្ឍន៍ ឬការផលិតប្រេង ដែលនឹងចែងលំអិតនៅក្នុងកិច្ចព្រមព្រៀងលើការបែងចែកផលិតផល គប្បីត្រូវបែងចែករវាងរាជរដ្ឋាភិបាល និងអ្នកជាប់កិច្ចសន្យា តាមសមាមាត្រដូចមានចែងក្នុងកិច្ចព្រមព្រៀងលើការចែកផលិតផល។

មាត្រា ៣៩ យោងទៅដល់ " ប្រាក់រង្វាន់សំរាប់ការចុះហត្ថលេខា " ដែលត្រូវបង់ក្នុងរយៈពេល ៣០ ថ្ងៃ ចាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចព្រមព្រៀងលើការបែងចែកផលិតផល និង "ប្រាក់រង្វាន់ផលិតកម្ម" ដែលត្រូវបង់ក្នុងរយៈពេល ៩០ ថ្ងៃបន្ទាប់ពីថ្ងៃលក់ដែលមានលក្ខណៈពាណិជ្ជកម្មលើកដំបូង។ កិច្ចព្រម-ព្រៀងលើការបែងចែកផលិតផល មានចែងអំពីប្រាក់រង្វាន់ដែលត្រូវបង់របៀបនេះ។

ក្រុមហ៊ុនឥណ្ឌូនេស៊ី Medco Energi Internsional បានផ្តល់ពត៌មានខ្លះៗអំពីលក្ខខណ្ឌនៃកិច្ចព្រមព្រៀងរបស់ខ្លួនជាមួយកម្ពុជា ទាក់ទងនឹងការរុករកនៅក្នុង ប្លុក E នៅក្នុងសេចក្តីប្រកាសជាសាធារណៈរបស់ខ្លួនក្នុង ខែតុលា ឆ្នាំ ២០០៦ ស្តីពីការចុះហត្ថលេខា[២៤]

- ការរុករកជំហានដំបូង នឹងមានរយៈពេលបីឆ្នាំ ហើយអាចពន្យាសំរាប់ជំហានទី២ និងទី៣ បាន រយៈពេល២ឆ្នាំ បន្តបន្ទាប់ ដោយមានការយល់ព្រមពីអាជ្ញាធរជាតិប្រេងកាតកម្ពុជា
- រដ្ឋាភិបាលកម្ពុជា ទទួលបានថ្លៃសួយសារ ១២,៥% នៃផលិតផល
- Medco និង JHL អាចកាត់ចំណាយរបស់ខ្លួន ពី ៩០% នៃផលិតផលដែលនៅសល់ សំរាប់ការចំណាយបច្ចុប្បន្ន និងឆ្នាំកន្លងមក។
- ផលិតផលចុងក្រោយត្រូវបានទុក " ស្របទៅតាមបទបញ្ញត្តិស្តីពីប្រេងកាតរបស់កម្ពុជា "។
- Medco និង JHL បង់ពន្ធលើប្រាក់ចំណូលសាជីវកម្ម ៣០%។
- បន្ទាប់ពីផលិតកម្មទ្រង់ទ្រាយពាណិជ្ជកម្មលើកដំបូង អាជ្ញាធរជាតិប្រេងកាតកម្ពុជា មានជំរើសមួយ សំរាប់ ៥% " ផលប្រយោជន៍ការងារ "។
- Medco បានចំណាយអស់ ៤,៥ លានដុល្លារ ជា " មូលនិធិសំរាប់គំរោងអភិវឌ្ឍន៍សង្គម " ដល់ប្រទេសកម្ពុជា។

២៤ /www.medcoenergi.com/press_release/04oct06_acquired_block_e_offshore_cambodia.pdf

**ច្បាប់ទាក់ទងនឹងតម្លាភាពនៃចំណូល និងការត្រួតពិនិត្យថវិកា**

គួរមានច្បាប់ទូទៅទាក់ទងនឹងការបើកចំហ និងការត្រួតពិនិត្យចំណូលរបស់រដ្ឋាភិបាល ព្រមទាំងការគ្រប់គ្រងថវិកា ហើយច្បាប់ទាំងនេះក៏ពាក់ព័ន្ធនឹងចំណូលពីប្រេងដែរ។ រដ្ឋសភាក៏នឹងត្រូវដើរតួជាអ្នកត្រួតពិនិត្យមួយដែរ ដែលក្នុងនោះរួមមានគណៈកម្មការនានាដែលមានការទទួលខុសត្រូវជាក់លាក់ សំរាប់ត្រួតពិនិត្យលំហូរនៃប្រាក់ចំណូល។

***ការគ្រប់គ្រងប្រាក់ចំណូល និងការរៀបចំថវិកា***

**កម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** (PFMRP)

នៅឆ្នាំ ២០០៤ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តួចផ្តើមកម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ[២៥] ។ កម្មវិធីនេះមានបួនដំណាក់កាលបន្តបន្ទាប់គ្នា ឬគោលការណ៍ ចាប់ពីឆ្នាំ ២០០៤ ដល់ ២០១៥ ។

១. គំរោងថវិកាដែលកាន់តែជឿទុកចិត្តបាន

២. គណនេយ្យភាពហិរញ្ញវត្ថុកាន់តែមានប្រសិទ្ធភាព

៣. កម្មវិធីគោលនយោបាយដែលអាចធ្វើទៅបាន តាមរយៈការផ្សារភ្ជាប់ គោលនយោបាយ និងថវិកា

៤. គណនេយ្យភាពសំរាប់ការអនុវត្តកម្មវិធីប្រកបដោយប្រសិទ្ធភាព។

PFMRP ត្រូវបានគាំទ្រដោយគំរោងគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណនេយ្យភាព រឹងមាំរបស់ធនាគារពិភពលោក ដែលទទួលហិរញ្ញវត្ថុរួមគ្នាពីម្ចាស់ជំនួយមួយចំនួន ដែលក្នុងនោះរួមមាន AusAid, DfID និងសហភាពអឺរ៉ុប ហើយថវិកាចំនួន ២ លានដុល្លារ ត្រូវលៃទុកសំរាប់ចំណាយលើបញ្ហាទាក់ទងនឹងការគ្រប់គ្រងចំណូលពីប្រេង សំរាប់ឆ្នាំ ២០០៧។ ធនាគារពិភពលោក កំពុងផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋាភិបាលកម្ពុជា ដើម្បីជួយឱ្យរដ្ឋាភិបាលពិចារណាទៅលើជំរើសទាំងឡាយក្នុងការគ្រប់គ្រងចំណាយ ក្នុងគោលបំណងឱ្យរដ្ឋាភិបាលបង្កើត *ឯកសារស* មួយ (ពោលគឺជាឯកសារពិគ្រោះយោបល់សាធារណៈមួយ ដែលដាក់ចេញនូវជំរើស ដោយមានអំណះអំណាងគាំទ្រ និងអំណះអំណាងប្រឆាំង) ស្តីពីជំរើសក្នុងការគ្រប់គ្រងចំណូលបានពីប្រេង។ រដ្ឋាភិបាល និងធនាគារពិភពលោកកំពុងជជែកគ្នាលើបញ្ហានេះ នៅក្នុងបរិបទនៃជំរើសសំរាប់គាំទ្រដល់ការកាត់បន្ថយភាពក្រីក្រ[២៦] ។ គេកំពុងរៀបចំឯកសារស្តីពីគោលនយោបាយចំណាយ ដែលនឹងត្រូវចែកចាយ ដើម្បីការពិភាក្សា។

---

[២៥] www.mef.gov.kh

[២៦] ជំរើសសំរាប់គាំទ្រដល់ការកាត់បន្ថយភាពក្រីក្រ (PRSO)។ រៀងរាល់ឆ្នាំ រដ្ឋាភិបាល និងធនាគារពិភពលោក កំណត់កម្មវិធីកំណែទំរង់នយោបាយសំខាន់ៗចំនួន ១០ ចំណុច ដែលភាគច្រើនបំផុតជាសកម្មភាពលំអិត ផ្អែកលើសូចនាករសំរាប់ការត្រួតពិនិត្យរួមគ្នា ហើយធនាគារពិភពលោកផ្តល់ឱ្យរដ្ឋាភិបាលកម្ពុជា ១៥ លានដុល្លារក្នុងមួយឆ្នាំ បើរដ្ឋាភិបាលធ្វើការនេះបានសំរេច ។

**វេទិកាសេដ្ឋកិច្ចនៃកម្ពុជា (CEF) /ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC)**

កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ បានគាំទ្រដល់ការបើកឱ្យមានវេទិកាសេដ្ឋកិច្ចនៃកម្ពុជាដែលផ្តួចផ្តើមដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ នៅក្នុងខែមករា ២០០៦ ដែលពេលនោះមានការពិចារណាទៅលើបញ្ហាប្រេង និងឧស្ម័ន ហើយដែលបានគាំទ្រដល់អត្ថបទនិពន្ធមួយចំនួនដែលត្រូវបានយោងក្នុងឯកសារនេះ[២៧]។ វេទិកាសេដ្ឋកិច្ចនៃកម្ពុជាបានចូលរួមជាអធិបតីពីសំណាក់នាយករដ្ឋមន្ត្រី។ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិបានស្នើឱ្យមានកម្មវិធីស្រាវជ្រាវតាមដានស៊ីជំរៅមួយ រួមជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដើម្បីស្វែងរកគោលនយោបាយចាំបាច់ វិធានការពារផ្នែកស្ថាប័ន និងផ្នែកច្បាប់ ដើម្បីជៀសវាងបណ្តាសារប្រេង ក្នុងគោលដៅបង្កើតនូវទំរង់គោលនយោបាយ និងជំរើសខាងស្ថាប័ន។ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិបាននិយាយថា ខ្លួននឹងគាំទ្រដល់វេទិកាសេដ្ឋកិច្ចនៃកម្ពុជាលើកទី២ ដើម្បីតាមដានបញ្ហាដែលលេចឡើងថ្មីៗ [២៨]។

**គំនិតផ្តួចផ្តើមនៃតម្លាភាពខាងឧស្សាហកម្មនិស្សារណកម្ម** (Extractive Industry Transparency Initiative = EITI)

ធនាគារពិភពលោក បានរៀបចំសិក្ខាសាលាមួយសំរាប់រដ្ឋសភា ស្តីពី EITI នៅក្នុងខែសីហា ឆ្នាំ ២០០៦[២៩] ហើយបន្ទាប់ពីសិក្ខាសាលានោះ ក៏មានកិច្ចប្រជុំ និងកិច្ចពិភាក្សាជាបន្តបន្ទាប់។ ដូចគ្នានេះដែរ នៅខែវិច្ឆិកា ២០០៦ មន្ត្រីជាន់ខ្ពស់មកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចូលរួមក្នុងសន្និសិទស្តីពី EITI នៅក្រុងអូស្លូ ប្រទេសណរវ៉េស។ ធនាគារពិភពលោក និងរាជរដ្ឋាភិបាលកំពុងពិភាក្សាពី EITI ដែលជាផ្នែកមួយនៃជំរើសដើម្បីគាំទ្រដល់ការកាត់បន្ថយភាពក្រីក្រ (PRSO)។

---

កំណែទំរង់មួយឈុតចុងក្រោយ ត្រូវបានកំណត់ នៅខែធ្នូ ឆ្នាំ ២០០៤ ដែលកាលនោះ ប្រេងមិនទាន់ត្រូវបានគេមើលឃើញថាជាបញ្ហាដែលទាមទារឱ្យចាត់វិធានការគោលនយោបាយបន្ទាន់នៅឡើយ។ ថវិកាសំរាប់ ជំរើសសំរាប់គាំទ្រដល់ការកាត់បន្ថយភាពក្រីក្រលើកទីមួយ ត្រូវបានគេគ្រោងថានឹងផ្តល់ក្នុងឆ្នាំ ២០០៧។

[២៧] ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៩ ដោយអនុក្រិត្យ ដើម្បីផ្តល់ដល់នាយករដ្ឋមន្ត្រី នូវធនធានសំរាប់យុទ្ធសាស្ត្រសេដ្ឋកិច្ច-សង្គម និងការបង្កើតគោលនយោបាយ ព្រមទាំងការផ្តល់យោបល់ ។ ធនាគារអភិវឌ្ឍន៍អាស៊ីជាអ្នកផ្តល់ការគាំទ្រ ផ្នែកបច្ចេកទេស។

[២៨] ទំព័រ ១ នៃ ទស្សនៈការងាររបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ស្តីពីការជំពាក់វ៉ាក់វិនខាងសេដ្ឋកិច្ច-សង្គម សំរាប់កម្ពុជានូវប្រេង និងឧស្ម័ន, ខែមិថុនា ឆ្នាំ ២០០៦។

[២៩] ឯកសារនៃបទបង្ហាញ មានជាឯកសារបោះពុម្ព " *ឯកសារ : ការត្រួតពិនិត្យរបស់រដ្ឋសភា លើចំណូលប្រេង* " ។